# ក

# មាតិកា

## I_ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


១៦-៨-២០០៣ -ព្រះរាជក្រឹត្យ នស/រកត/០៨០៣/២៥៥ស្តីពី ការតម្លើងឋានន្តរសក្តិថ្នាក់ **ឧត្តមសេនីយ៍ត្រី** ជាកិច្ចបច្ឆាមរណៈចំពោះ សពលោកវរៈសេនីយឯក **សេង សានផលី** ២៨៥៣

១៦-៨-២០០៣ -ព្រះរាជក្រឹត្យ នស/រកត/០៨០៣/២៥៥ ស្តីពី ការតម្លើងឋានន្តរសក្តិថ្នាក់ **ឧត្តមសេនីយ៍ត្រី** ជាកិច្ចបច្ឆាមរណៈចំពោះ សពលោកវរៈសេនីយឯក **ម៉ី ស៊ីន** ២៨៥៤

១៦-៨-២០០៣ -ព្រះរាជក្រឹត្យ នស/រកត/០៨០៣/២៥៧ ស្តីពី ការផ្តល់សញ្ជាតិខ្មែរតាមសញ្ជាតូបនីយកម្ម ដល់
១-លោក **ខៅ ឧនសៀង** ដោយប្តូរឈ្មោះ **ខៅ ម៉េងអាន** ជនជាតិចិន សញ្ជាតិម៉ាឡេស៊ី
២-អ្នកស្រី **ហ្វុន គ្រាគីនហ្វុន** ដោយប្តូរឈ្មោះ **ចំនួ ហ៊ុងអ៊ីង** ជនជាតិចិន សញ្ជាតិអង់គ្លេស ២៨៥៥

១៦-៨-២០០៣ -ព្រះរាជក្រឹត្យ នស/រកត/០៨០៣/២៥៨ ស្តីពី ការតែងតាំងឯកឧត្តម **លី គឹមឡេង** ជាអគ្គលេខាធិការរង នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បន្ថែមលើមុខងារបច្ចុប្បន្ន មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ២៨៥៦

១៦-៨-២០០៣ -ព្រះរាជក្រឹត្យ នស/រកត/០៨០៣/២៥៩ ស្តីពី ការតែងតាំងលោក **ឈុន អួន** ជា **ឧកញ៉ា** ២៨៥៧

១៦-៨-២០០៣ -ព្រះរាជក្រឹត្យ នស/រកត/០៨០៣/២៦០ ស្តីពី ការតែងតាំងលោក **ម៉ិច ភ្នួះ** ជា **ឧកញ៉ា** ២៨៥៨

១៩-៨-២០០៣ -ព្រះរាជក្រឹត្យ នស/រកត/០៨០៣/២៦២ ស្តីពី ការផ្តល់សញ្ជាតិខ្មែរតាមសញ្ជា តូបនីយកម្មដល់
១-លោក **យូ ទាំងយុង** (U WANG YOUNG) សញ្ជាតិដើមភូមាកើតនៅក្រុងយ៉ាងហ្គូនប្រទេសភូមា
២-អ្នកស្រី **ណានអេយើណុន** (NAN AYE NUN)សញ្ជាតិដើមភូមា កើតនៅក្រុងយ៉ាងហ្គូន ប្រទេសភូមា ២៨៥៩


## II_រាជរដ្ឋាភិបាល

### ១_អនុក្រឹត្យ


១៨-០៨-២០០៣ -អនុក្រឹត្យលេខ ៧៤២ អនក្រ.តត ស្តីពី ការតម្លើងឋានន្តរស័ក្តិនាយនគរបាលជាតិ ជាកិច្ចបច្ឆាមរណៈ ២៨៦០

១៩-០៨-២០០៣ -អនុក្រឹត្យលេខ ៧៤៣ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ២៨៦១

| | | |
|---|---|---|
| ១៩-០៨-២០០៣ | -អនុក្រឹត្យលេខ ៧៤៤ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ | ២៨៦២ |
| ១៩-០៨-២០០៣ | -អនុក្រឹត្យលេខ ៧៤៥ អនក្រតត ស្តីពី ការតែងតាំងមន្ត្រីរាជការ | ២៨៦៣ |
| ២០-០៨-២០០៣ | -អនុក្រឹត្យលេខ ៧៤៦ អនក្រតត ស្តីពី ការជូនមេដាយស្ថាបនាជាតិ | ២៨៦៤ |
| ២០-០៨-២០០៣ | -អនុក្រឹត្យលេខ ៧៤៧ អនក្រតត ស្តីពី ការជូនមេដាយស្ថាបនាជាតិ | ២៨៦៥ |
| ២០-០៨-២០០៣ | -អនុក្រឹត្យលេខ ៧៤៨ អនក្រតត ស្តីពី ការជូនមេដាយស្ថាបនាជាតិ | ២៨៦៦ |
| ២១-០៨-២០០៣ | -អនុក្រឹត្យលេខ ៧៤៩ អនក្រតត ស្តីពី ការជូនមេដាយការងារ | ២៨៦៧ |
| ២១-០៨-២០០៣ | -អនុក្រឹត្យលេខ ៧៥០ អនក្រតត ស្តីពី ការជូនមេដាយស្ថាបនាជាតិ | ២៨៦៨ |
| ២២-០៨-២០០៣ | -អនុក្រឹត្យលេខ ៧៥១ អនក្រតត ស្តីពី ការជូនមេដាយសុវត្ថារា | ២៨៦៩ |
| ២២-០៨-២០០៣ | -អនុក្រឹត្យលេខ ៧៥២ អនក្រតត ស្តីពី ការជូនមេដាយការងារ | ២៨៧១ |


## ២-សេចក្តីសម្រេច


| | | |
|---|---|---|
| ១៤-០៨-២០០៣ | - សេចក្តីសំរេចលេខ ៦០ សសរ ស្តីពី ការផ្ទេរសិទ្ធិ | ២៨៧៦ |
| ១៨-០៨-២០០៣ | - សេចក្តីសំរេចលេខ ៦១ សសរ ស្តីពី ការបង្កើតគណៈកម្មការទាក់ទងជាមួយសមភាគីថៃ និង ដោះស្រាយការងារពាក់ព័ន្ធនិងការអនុវត្តគំរោងសាងសង់ផ្លូវជាតិ លេខ ៦៧ ( ច្រកសាងាំ អន្លង់វែង សៀមរាប) | ២៨៧៨ |


## ៣-សារាចរ


| | | |
|---|---|---|
| ២០-០៨-២០០៣ | -សារាចរលេខ ០២ សរ ស្តីពី ការគ្រប់គ្រង និងការប្រើប្រាស់ត្រានៅតាមក្រសួង-ស្ថាប័ន | ២៨៧៩ |


## ៤-សារាចរណែនាំ


| | | |
|---|---|---|
| ២១-០៨-២០០៣ | - សារាចរណែនាំលេខ ១២ សរណន ស្តីពី ការប្រារព្ធទិវាអក្ខរកម្មជាតិ ៨ កញ្ញា | ២៨៨០ |


## III-ការងារបណ្តាក្រសួង

## ទីស្តីការរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍


| | | |
|---|---|---|
| ១៥-០៨-២០០៣ | - ប្រកាសលេខ ២៧២ បទ.ប្រក.ស្តីពី ការគ្រប់គ្រងបរិក្ខារវិទ្យុគមនាគមន៍ និងថ្លៃប្រើប្រាស់រលកអាកាសវិទ្យុ | ២៨៨៣ |
| ១៥-០៨-២០០៣ | -ប្រកាសលេខ ២៧៣ បទ.ប្រក. ស្តីអំពី សេវាជួលជាវបរិបថទូរគំនាគមន៍អក្ខរៈលេខ ( Digital Leased Capacity ) | ២៨៩៣ |

# ព្រះរាជក្រឹត្យ

នស/រកត/០៨០៣/២៨៥

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

## ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : តម្លើងឋានន្តរសក្តិ ថ្នាក់ **ឧត្តមសេនីយ៍ត្រី** ជាកិច្ចបច្ចាមរណៈ ចំពោះសពលោកវរសេនីយ៍ឯក **សេងសាន្ត ផលលី** អត្តលេខ ០០៧៧ អនុប្រធានទី១ អង្គភាពអន្តរាគមន៍ ក្រសួងមហាផ្ទៃ ។

**មាត្រា ២** : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ៕

**ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ**

**នរោត្តម សីហនុ**

៣រល.០៣.០៨.៤៦៦

លេខៈ ២១៣ ចល

ដើម្បីចម្លងចែក

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០០៣

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០០៣

អគ្គលេខាធិការរាជរដ្ឋាភិបាល

[illegible] សាន់

# ព្រះរាជក្រឹត្យ

នស/រកត/០៨០៣/២៥៦

## យើង

## ព្រះបាទសម្ដេចព្រះ នរោត្ដម សីហនុ

## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
## និករោត្ដម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
## ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្ដីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយ របស់សម្ដេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១**: តម្លើងឋានន្តរសក្ដិ ថ្នាក់ **ឧត្ដមសេនីយ៍ត្រី** ជាកិច្ចបច្ឆាមរណៈ ចំពោះសពលោកវរសេនីយ៍ឯក **ម៉ី ស៊ីន** អត្តលេខ ០២៧១ អនុប្រធាននាយកដ្ឋានបំភ័ន្តអក្ខរៈ ក្រសួងមហាផ្ទៃ ។

**មាត្រា ២**: សម្ដេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣**: ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ដលេខានេះតទៅ ។

**ព្រះហស្ដលេខា និង ព្រះរាជលញ្ឆករ**

**នរោត្ដម សីហនុ**

៣ស-០៣-០៨.២៦៧

លេខ:២១២ ច ល

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០០៣*

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ.ថ្ងៃទី ១៨ ខែ ៨/៣ ឆ្នាំ២០០៣

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

[illegible] តាន់

# ព្រះរាជក្រឹត្យ

នស/រកត/០៨០៣/២៥៧

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់ :

១- លោក **ខៅ នុនសៀង** ដោយប្តូរជាឈ្មោះ **ខៅ ម៉េងអាន** ជនជាតិចិន សញ្ជាតិម៉ាឡេស៊ី កើតថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ១៩៥៦ ។

២- អ្នកស្រី **ហួន គ្រាសគីនហួន** ដោយប្តូរជាឈ្មោះ **ច័ន្ទ ហ៊ុងអ៊ីង** ជនជាតិចិន សញ្ជាតិអង់គ្លេស កើតថ្ងៃទី ២២ ខែ សីហា ឆ្នាំ ១៩៥៨ ។

**មាត្រា ២** : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ៕

**ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ**

**នរោត្តម សីហនុ**

លេខ: ២១៤៥ ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ ៨/៣ ឆ្នាំ២០០៣

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

ឈាងី តាន់

៣រល-០៣-០៧-២៦៧

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០០៣*

# ព្រះរាជក្រឹត្យ

នស/រកត/០៨០៣/២៥៨

**យើង**

**ព្រះបាទសម្ដេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៩៩៥/៦៥ ចុះថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ១៩៩៥ ស្ដីពីការបង្កើតអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយ របស់សម្ដេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១** : តែងតាំងឯកឧត្តម **លី គីមឆ្យុង** ជាអគ្គលេខាធិការរង នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បន្ថែមលើមុខងារបច្ចុប្បន្ន មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ។

**មាត្រា ២** : សម្ដេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ៕

**ព្រះហស្ថលេខា និង ព្រះរាជលញ្ឆករ**

**នរោត្តម សីហនុ**

ពរស-០៣.០៨.២៦៩

លេខ: ២០៩៥ច ល

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០០៣*

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ [illegible] ឆ្នាំ២០០៣

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

[illegible] តាន់

# ព្រះរាជក្រឹត្យ

នស/រកត/០៨០៣/២៥៩

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

( យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា )

**តែងតាំង**

**លោក ឈួន អួន**

**ជា**

**ឧកញ៉ា**

**ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ**

**នរោត្តម សីហនុ**

៣រល.០៣.០៨.៤៧០

លេខៈ ២១០ ច ល

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០០៣

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ ៨ ឆ្នាំ២០០៣

អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ាង តាន់

# ព្រះរាជក្រឹត្យ

នស/រកត/០៨០៣/២៦០

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**
**រាជហរិវង្ស ឧភតោសុជាត ជិសុទ្ធពង្ស អគ្គមហាបុរសរតន៍**
**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**
**ព្រះចៅក្រុងកម្ពុជាធិបតី**

( យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា )

**តែងតាំង**

**លោក ម៉ឹង ភូមិ**

**ជា**

**ឧកញ៉ា**

**ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ**

៣៤ល-០៣.០៨.៧៧១ **នរោត្តម សីហនុ** លេខ: ២១១ ច ល

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០០៣

ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ ៨/៧ ឆ្នាំ២០០៣
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

[illegible] តាន់

# ព្រះរាជក្រឹត្យ

នស/រកត/០៨០៣/២៦២

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១** : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់ :

១- លោក **យូ វ៉ាំង យ៉ុង** ( U WANG YOUNG ) សញ្ជាតិដើមភូមា កើតនៅថ្ងៃទី ១១ ខែ មេសា ឆ្នាំ ១៩៦២ នៅក្រុងយ៉ាំងហ្គូន ប្រទេសភូមា ។

២- អ្នកស្រី **ណាន អេយ៉ីនុន** ( NAN AYE NUN ) ( ភរិយា ) សញ្ជាតិដើមភូមា កើតនៅថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ១៩៦៧ នៅក្រុងយ៉ាំងហ្គូន ប្រទេសភូមា ។

**មាត្រា ២** : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ**

**នរោត្តម សីហនុ**

ពរស-០៣.០៨.២៧៣

លេខ: ២១៥ច ល

ដើម្បីចម្លងចែក

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០០៣

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ សីហា ឆ្នាំ២០០៣

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

ណារី តាន់

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៧៤៧ អនក្រ.បក

# អនុក្រឹត្យ

## ស្ដីពី

## ការតម្លើងឋានន្តរសក្តិនាយនគរបាលជាតិ

## ជាកិច្ចបច្ឆាមរណៈ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ / ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/ រកម / ០១៩៦ /០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៥០១ / ១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១ :** ត្រូវបានតម្លើងឋានន្តរសក្តិថ្នាក់ **វរសេនីយ៍ឯក** ជាកិច្ចបច្ឆាមរណៈ ជូនចំពោះសពលោកវរសេនីយ៍ទោ **ឌូ សារុន** អត្តលេខ ០៦៦៤ នាយការិយាល័យគណនេយ្យ នាយកដ្ឋានភស្តុភារ និងសំភារៈបច្ចេកទេស នៃក្រសួងមហាផ្ទៃ ។

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០០៣*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

*កន្លែងទទួល*
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *ឯកសារ កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៧៤៣ . អនក្រ. តត

# អនុក្រឹត្យ

## ស្តីពីការតែងតាំងមន្ត្រីរាជការ

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៤០១ / ០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់ នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ

**សំរេច**

**មាត្រា១ :** ត្រូវបានតែងតាំងលោក **ជីង ប៊ុនថេង** អតីតអគ្គទីប្រឹក្សាស្ថានឯកអគ្គរាជទូតកម្ពុជា ប្រចាំព្រះរាជាណាចក្រថៃឡង់ដ៍ ជាអគ្គលេខាធិការរង ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ។

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និង សាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០០៣*

ហ៊ុន សែន

**កន្លែងទទួល:**
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ: ៧៨៨ . អនក្រ . តត

# អនុក្រឹត្យ
## ស្តីពីការតែងតាំងមន្ត្រីរាជការ

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៤០១ / ០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់ នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ

**សម្រេច**

**មាត្រា១ :** ត្រូវបានតែងតាំងលោក **ជេត ណារ៉េន** បច្ចុប្បន្នអនុប្រធាននាយកដ្ឋាន នៃអគ្គនាយកដ្ឋានអាស៊ាន ជាអគ្គនាយករងនៃអគ្គនាយកដ្ឋានអាស៊ាន នៃក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ។

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និង សាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែសីហា ឆ្នាំ ២០០៣*

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល:**
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *ឯកសារ-កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៧៤៥ . អនក្រ . តត

## អនុក្រឹត្យ
## ស្តីពីការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៤០១ / ០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់ នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ

## សំរេច

**មាត្រា១ :** ត្រូវបានតែងតាំងលោក **ស៊ិន សួន** អតីតអគ្គរាជទូតនិងតំណាងអចិន្ត្រៃយ៍រង នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំអង្គការសហប្រជាជាតិ មន្ត្រីថ្នាក់អនុប្រធាននាយកដ្ឋាន ជាប្រធាននាយកដ្ឋានអាមេរិក នៃក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ។

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និង សាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០០៣

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ..៧៥៤៦...អនក្រ-បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សំរេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ជូនសប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក ចំនួន០៧រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ចូលរួមចំណែកក្នុងការកសាងស្ពានថ្មខ្សឹង នៅភូមិចកកើត ឃុំរហាត់ទឹក ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ ដូចមានរាយនាមខាងក្រោម :-

**ក-មេដាយមាសស្ថាបនាជាតិ :**

-លោក **សេក ម៉ុន** និង អ្នកស្រី **កែវ អួន** ថវិកា ១០.៣៣៥.៥០ ដុល្លារអាមេរិក

**ខ-មេដាយប្រាក់ស្ថាបនាជាតិ :**

-លោកតា **វើយ គោះ** និង លោកយាយ **យូ វ៉ាន** ថវិកា ៦.១២៩.៥០ ដុល្លារអាមេរិក

**គ-មេដាយសំរិទ្ធស្ថាបនាជាតិ :**

១-លោក **ហៀប វឿន** ថវិកា ២.៩៧៩.៨០ ដុល្លារអាមេរិក

២-លោកយាយ **តាំង ចេង** និង លោកយាយ **ហេង តូច** ថវិកា ២.៥០០ ដុល្លារអាមេរិក

៣-ឧបាសិកា **ហៀប ស៊ុំ** ថវិកា ១.៦០០ ដុល្លារអាមេរិក

៤-លោក **សួស ខុន** ថវិកា ១.២១៩ ដុល្លារអាមេរិក

៥-លោក **គីម ម៉ៅ** និងអ្នកស្រី **យូ ពេញ** ថវិកា ១.១៤៨.៥០ ដុល្លារអាមេរិក

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តបន្ទាយមានជ័យ ត្រូវ អនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ សីហា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខៈ ៧២៤ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ អភិបាលខេត្តបាត់ដំបង

## ស ំ រេ ច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ចំនួន ០៤រូប ដែលបានខិតខំអស់ពីកំលាំង កាយចិត្ត និង បរិច្ចាគធនធានផ្ទាល់ខ្លួន រួមចំណែកក្នុងការកសាងមជ្ឈមណ្ឌលកុមារកំព្រាឥស្លាម តាកុក នៅក្នុង ឃុំនរា ស្រុកសង្កែ ខេត្តបាត់ដំបង ដូចមានរាយនាមខាងក្រោម :-

| | | | |
|---|---|---|---|
| ១-លោក | **សុះ មូហាំម៉ាត់** | ថវិកា | ៧០.៨០០ ដុល្លារអាមេរិក |
| ២-ឯកឧត្តម | **សាន់ សាលីន** | ថវិកា | ៦៩.៣០០ ដុល្លារអាមេរិក |
| ៣-លោក | **មូហាំម៉ាត់ហ្សេន ការីមេល** | ថវិកា | ៣៤.៧៥០ ដុល្លារអាមេរិក |
| ៤-លោក | **សែម សុខា** | ថវិកា | ១៦.០០០ ដុល្លារអាមេរិក |

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ និង អភិបាលខេត្តបាត់ដំបង ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

87

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៧៧៤៨ ... អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ

**ស ម្រេ ច**

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ចំនួន០១គ្រឿង ប្រគេនព្រះតេជគុណ **ផាត់ ផុន** ព្រះអនុគណ-ស្រុក និង ជាព្រះចៅអធិការ វត្តជ័យឧត្តម-ចុងកាល់ ដែលបានខិតខំអំពាវនាវសប្បុរសជន នៅក្នុង និង ក្រៅប្រទេស បានបច្ច័យមកកសាង ព្រះវិហារ កុដិ សាលាបាលី ក្លោងទ្វារ របង និង សមិទ្ធផលផ្សេងៗទៀត នៅក្នុងវត្តជ័យឧត្តម-ចុងកាល់ ស្រុកចុងកាល់ ខេត្តឧត្តរមានជ័យ ចំណាយអស់បច្ច័យ សរុបចំនួន ៧០.៨៣៥ ដុល្លារអាមេរិក និង ១៣១.៩១២.៨៦៧ រៀល ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តឧត្តរមានជ័យ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ សីហា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខៈ...៣៥៤៩...អនក្រ.តត

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយការងារ

---

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស

**ស ំ រេ ច**

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមាសការងារ** ជូនទីប្រឹក្សា និង នាយករងខុទ្ទកាល័យ សម្តេចប្រធានព្រឹទ្ធសភា ចំនួន ០២រូប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ច ជូនជាតិមាតុភូមិ ដូចមានរាយនាមខាងក្រោម :-

១-ឯកឧត្តម **ឯក ស៊ុនចាន់** ទីប្រឹក្សាសម្តេចប្រធានព្រឹទ្ធសភា

២-ឯកឧត្តម **ឡោក ម្សារ** នាយករងខុទ្ទកាល័យ សម្តេចប្រធានព្រឹទ្ធសភា

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូន គ្រឿងឥស្សរិយយស ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួល បានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៨៥០...អនក្រ.បក

## អនុក្រឹត្យ
## ស្ដីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្ដីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា

## ស ម្រេ ច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ប្រគេនព្រះតេជគុណ **ឡាំ អ៊ិត** ព្រះចៅអធិការវត្ត ពោធិដំណាក់ និង ជាលេខាធិការអនុគណស្រុកស្ទោង ដែលបានខិតខំអំពាវនាវពុទ្ធបរិស័ទ ពីគ្រប់មជ្ឈដ្ឋាន នៅក្នុង និង ក្រៅប្រទេស ព្រមទាំងបច្ច័យផ្ទាល់របស់ព្រះអង្គ យកមកកសាងព្រះវិហារ សាលាឆាន់ កុដិ សាលាបាលី របង និងចាក់ដីទីធ្លាក្នុងវត្ត ពោធិដំណាក់ ឃុំចំណារក្រោម ស្រុកស្ទោង ខេត្តកំពង់ធំ ចំណាយអស់បច្ច័យ សរុបចំនួន ១៣.៤១៥ ដុល្លារអាមេរិក ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា និង អភិបាលខេត្តកំពង់ធំ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួល បានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខៈ...៧៥១...អនក្រ.បក

**អនុក្រឹត្យ**

**ស្តីពីការជូនមេដាយសុវត្ថារា**

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃ គណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រី ក្រសួងផែនការ

**សំរេច**

**មាត្រា ១:** ត្រូវបានបំពាក់ **មេដាយសុវត្ថារា** ថ្នាក់ **សេនា** ជូនមន្ត្រីរាជការចំនួន ១៥ រូប ក្រោមឱវាទក្រសួងផែនការ ដែលមានស្នាដៃល្អ ក្នុងការបំពេញភារកិច្ច បំរើជាតិមាតុភូមិ ដូចមានរាយនាមខាងក្រោមៈ

| | |
|---|---|
| ១-ឯកឧត្តម **ឆ៊ីន លាវ** | អគ្គាធិការ នៃអគ្គាធិការដ្ឋាន |
| ២-ឯកឧត្តម **ហ៊ូ តាំងអេង** | អគ្គនាយក នៃអគ្គនាយកដ្ឋានផែនការ |
| ៣-ឯកឧត្តម **សន ស៊ីថន** | នាយក នៃវិទ្យាស្ថានជាតិស្ថិតិ |
| ៤-លោក **ឌួន ថាវរៈ** | អគ្គនាយករង នៃអគ្គនាយកដ្ឋានផែនការ |
| ៥-លោកស្រី **ហ៊ាង សៀកលី** | អគ្គនាយករង នៃអគ្គនាយកដ្ឋានផែនការ |
| ៦-លោក **នុត ចន្ទសុខា** | អគ្គនាយករង នៃអគ្គនាយកដ្ឋានផែនការ |

| | |
|---|---|
| ៨-លោក **ខៀវ សារី** | នាយករង នៃវិជ្ជាស្ថានជាតិស្ថិតិ |
| ៩-លោកស្រី **ហង់ លីណា** | នាយករង នៃវិជ្ជាស្ថានជាតិស្ថិតិ |
| ១០-លោក **កោះ សំអុល** | ប្រធាននាយកដ្ឋានផ្គត់ផ្គង់ និងហិរញ្ញវត្ថុ |
| ១១-លោក **ខន្ធ សារ៉ុន** | ប្រធាននាយកដ្ឋាន បុគ្គលិក |
| ១២-លោក **កែវ សម្បត្តិ** | ប្រធាននាយកដ្ឋាន រដ្ឋបាលទូទៅ |
| ១៣-លោកស្រី **ឯម សារឿន** | ប្រធាននាយកដ្ឋានស្ថិតិសង្គមកិច្ច |
| ១៤-លោក **ហ៊ីង ចន្ទម៉ុន្ថា** | ប្រធាននាយកដ្ឋាន ផែនការវិនិយោគ |
| ១៥-លោក **ម៉ម ម៉ារ៉ាឌី** | ប្រធាននាយកដ្ឋានផែនការទូទៅ |

**មាត្រា ២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងផែនការ ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យទទួលបានលទ្ធផលល្អ ។/.

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា១ និង មាត្រា ២
-រាជកិច្ច /
-ឯកសារ- កាលប្បវត្តិ

រាជធានីភ្នំពេញ , ថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៣

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧៥៤ អនក្រ.តត

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយការងារ

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃ គណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រី ក្រសួងផែនការ

### ស ម្រេ ច

**មាត្រា ១**: ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ជូនមន្ត្រីរាជការចំនួន ១០៩ រូប ក្រោមឱវាទក្រសួងផែនការ ដែលមានស្នាដៃល្អ ក្នុងការបំពេញភារកិច្ច ជូនជាតិមាតុភូមិ ដូចមានរាយនាមខាងក្រោម:

**ក. មេដាយមាសការងារ:**

| | |
|---|---|
| ១-លោក **ហ៊ូ ហួរ** | អគ្គាធិការរង នៃអគ្គាធិការដ្ឋាន |
| ២-លោក **លឹម លឹមហ៊ាង** | អគ្គាធិការរង នៃអគ្គាធិការដ្ឋាន |
| ៣-លោកស្រី **ខៀវ ប៊ូរី** | ប្រធាននាយកដ្ឋានផែនការសង្គមកិច្ច |
| ៤-លោក **សោម សើវុឌ្ឍន៍** | ប្រធាននាយកដ្ឋានផែនការសេដ្ឋកិច្ច |
| ៥-លោកស្រី **ដួច សារុន** | អធិការ នៃអគ្គាធិការដ្ឋាន |

| | |
|---|---|
| ៦-លោក **យ៉េម សួន** | ប្រធាននាយកដ្ឋានស្ថិតិសង្គមកិច្ច |
| ៧-លោក **ទី ហៀង** | ប្រធាននាយកដ្ឋាន ស្ថិតិទូទៅ |
| ៨-លោក **ប៊ូ សុភាព** | អធិការ នៃអគ្គាធិការដ្ឋាន |
| ៩-លោក **ឃីម តាំង** | អនុប្រធាននាយកដ្ឋានបុគ្គលិក |
| ១០-លោក **ឈិល មួន** | អនុប្រធាននាយកដ្ឋានបុគ្គលិក |
| ១១-លោក **ឈន ណាង** | អនុប្រធាននាយកដ្ឋានបុគ្គលិក |
| ១២-លោកជំទាវ **ជុំ ស៊ីណា** | អនុប្រធាននាយកដ្ឋានរដ្ឋបាលទូទៅ |
| ១៣-លោក **គង់ សុផាត** | អនុប្រធាននាយកដ្ឋានផ្គត់ផ្គង់ និងហិរញ្ញវត្ថុ |
| ១៤-លោកស្រី **មាស សម្បត្តិ** | អនុប្រធាននាយកដ្ឋាន ផែនការវិនិយោគ |
| ១៥-លោក **យឹង ជឹម** | អនុប្រធាននាយកដ្ឋានរដ្ឋបាលទូទៅ |
| ១៦-លោក **ស៊ុំ លូអ៊ី** | អនុប្រធាននាយកដ្ឋានផែនការវិនិយោគ |
| ១៧-លោក **ឆែ ប៊ូ** | អនុប្រធាននាយកដ្ឋានផែនការទូទៅ |
| ១៨-លោក **ជា ចាន់ធុំ** | អនុប្រធាននាយកដ្ឋានផែនការទូទៅ |
| ១៩-លោក **ឡុង ឋិនថា** | អនុប្រធាននាយកដ្ឋានស្ថិតិប្រជាសាស្ត្រជំរឿន និងអង្កេត |
| ២០-កញ្ញា **តុង ឆៃរីន** | អនុប្រធាននាយកដ្ឋានស្ថិតិសេដ្ឋកិច្ច |
| ២១-លោក **គង់ ចិន្តា** | អនុប្រធាននាយកដ្ឋានស្ថិតិសង្គមកិច្ច |
| ២២-លោក **សៀង គីមហាន** | អនុប្រធាននាយកដ្ឋានស្ថិតិសង្គមកិច្ច |
| ២៣-លោកស្រី **ម៉ក់ សូនាង** | អនុប្រធាននាយកដ្ឋានផែនការសេដ្ឋកិច្ច |
| ២៤-លោក **ស៊ឹម ឆាយ** | ប្រធានការិយាល័យរបៀប |
| ២៥-លោក **ប៉ិច សុវណ្ណឌី** | អនុប្រធាននាយកដ្ឋានផែនការទូទៅ |

**ខ-មេជាយគ្រាក់ការខារះ**

| | |
|---|---|
| ១-លោក **ហាស់ ប៊ុនថ្លន** | ប្រធាននាយកដ្ឋានស្ថិតិប្រជាសាស្ត្រជំរឿន និងអង្កេត |
| ២-លោក **សាង សម** | អធិការ នៃអគ្គាធិការដ្ឋាន |
| ៣-លោក **និត្យ សុវណ្ណ** | អនុប្រធាននាយកដ្ឋាន ផែនការវិនិយោគ |
| ៤-លោក **អ៊ូ ឆោម** | អនុប្រធាននាយកដ្ឋាន បុគ្គលិក |
| ៥-លោក **មាន់ សារ៉ាត់** | អនុប្រធាននាយកដ្ឋានផែនការសង្គមកិច្ច |
| ៦-លោក **ស៊ិន សេដ្ឋា** | អនុប្រធាននាយកដ្ឋានផែនការសង្គមកិច្ច |
| ៧-លោកស្រី **ជុំ ពុទ្ធារី** | អនុប្រធាននាយកដ្ឋានផែនការសង្គមកិច្ច |
| ៨-លោក **ហួយ សិទ្ធិគុណ** | អនុប្រធាននាយកដ្ឋានផែនការសេដ្ឋកិច្ច |

| | |
|---|---|
| ៩-លោក ហាចុ្យ សុវិទ្យា | អនុប្រធាននាយកដ្ឋានផែនការទូទៅ |
| ១០-លោក មាន ថាវរៈ | អនុប្រធាននាយកដ្ឋានផែនការទូទៅ |
| ១១-លោកស្រី ជា កែវចន្នី | អនុប្រធាននាយកដ្ឋាន ផែនការវិនិយោគ |
| ១២-លោក វ៉េត រុងរឿង | អនុប្រធាននាយកដ្ឋាន ទំនាក់ទំនងអន្តរជាតិ |
| ១៣-លោកស្រី អ៊ិន សំអួន | អនុប្រធាននាយកដ្ឋានផែនការសង្គមកិច្ច |
| ១៤-លោក សាន សុខន | អនុប្រធាននាយកដ្ឋានផែនការសង្គមកិច្ច |
| ១៥-លោក កែវ ឫទ្ធា | អនុប្រធាននាយកដ្ឋានផែនការទូទៅ |
| ១៦-លោក ម៉ិច កន្ទុល | អនុប្រធាននាយកដ្ឋានស្ថិតិសេដ្ឋកិច្ច |
| ១៧-លោក ឡេង រ៉ាន | អនុប្រធាននាយកដ្ឋានផែនការទូទៅ |
| ១៨-លោក ចណ្ណា សួន | អនុប្រធាននាយកដ្ឋានស្ថិតិសង្គមកិច្ច |
| ១៩-លោក នេត្រ សារឿន | អនុប្រធាននាយកដ្ឋានរដ្ឋបាលទូទៅ |
| ២០-លោកស្រី ម៉ា ស៊ីនាង | អនុប្រធាននាយកដ្ឋានផ្គត់ផ្គង់ និងហិរញ្ញវត្ថុ |
| ២១-លោកស្រី ឈុន ឆវី | ប្រធានការិយាល័យបៀវត្ស |
| ២២-លោកស្រី ស៊ិន ធារី | ប្រធានការិយាល័យរដ្ឋបាល នៃមជ្ឈមណ្ឌលបណ្តុះបណ្តាលផែនការ ស្ថិតិ |
| ២៣-លោក នឹម ស៊ីថា | ប្រធានការិយាល័យបណ្តុះបណ្តាល |
| ២៤-លោកស្រី ម៉ៅ សុផុន | ប្រធានការិយាល័យ |
| ២៥-លោកស្រី អ៊ូច មុនីសេដ្ឋា | ប្រធានការិយាល័យលទ្ធកម្ម |
| ២៦-លោក លុក សំគីស | ប្រធានការិយាល័យស្ថិតិទូទៅ |
| ២៧-លោក ម៉េង គីមហ៊ារ | ប្រធានការិយាល័យអភិវឌ្ឍន៍ប្រពន្ធ័កុំព្យូទ័រស្ថិតិទូទៅ |
| ២៨-លោក ចាន់ នីម៉ូល | ប្រធានការិយាល័យជំរឿន |
| ២៩-លោក អ៊ុក អ៊ាង | ប្រធានការិយាល័យស្ថិតិសង្គមកិច្ច |
| ៣០-លោកស្រី គ្រាក់ បុឡាវី | ប្រធានការិយាល័យស្ថិតិសុខាភិបាលវប្បធម៌និងសាសនា |
| ៣១-លោក ស៊ឹម ឡាយ | ប្រធានការិយាល័យពិធីការ |
| ៣២-លោកស្រី មាន យ៉ុន | មន្ត្រីការិយាល័យរដ្ឋបាលទូទៅ |
| ៣៣-លោកជំទាវ ខុន នារី | ប្រធានការិយាល័យអាស៊ាន |
| ៣៤-លោក រស់ ស៊ីនួន | ប្រធានការិយាល័យសំភារៈ |

**គ-មេដាយសំរឹទ្ធការងារ:**

| | |
|---|---|
| ១-លោក ឡាយ ដារិន | អនុប្រធាននាយកដ្ឋាន ទំនាក់ទំនងអន្តរជាតិ |
| ២-លោក ម៉ូ ម៉ៅ | អនុប្រធាននាយកដ្ឋាន ទំនាក់ទំនងអន្តរជាតិ |

៣-លោក **ម៉ម ប្ញូរ៉ាត់** អនុប្រធាននាយកដ្ឋានផែនការសង្គមកិច្ច

៤-លោក **សាំង ឡុងឌី** អនុប្រធាននាយកដ្ឋានស្ថិតិទូទៅ

៥-លោក **កែវ ចិត្រា** អនុប្រធាននាយកដ្ឋានស្ថិតិទូទៅ

៦-លោក **ឃិន សុខ** អនុប្រធាននាយកដ្ឋានស្ថិតិទូទៅ

៧-លោក **សារិន ប្រសិទ្ធិ** អនុប្រធាននាយកដ្ឋានស្ថិតិសេដ្ឋកិច្ច

៨-លោកស្រី **អ៊ុក សាម៉ាសាធី** អនុប្រធាននាយកដ្ឋានស្ថិតិសេដ្ឋកិច្ច

៩-លោក **ហោ ដារិទ្ធ** អនុប្រធាននាយកដ្ឋានស្ថិតិសេដ្ឋកិច្ច

១០-លោក **ធិត្យ វឌ្ឍ** អនុប្រធាននាយកដ្ឋានស្ថិតិសង្គមកិច្ច

១១-លោក **ទ្រី សុធារិទ្ធ** អនុប្រធាននាយកដ្ឋានស្ថិតិសង្គមកិច្ច

១២-លោក **នុត សេដ្ឋា** អនុប្រធាននាយកដ្ឋាន ទំនាក់ទំនងអន្តរជាតិ

១៣-លោក **ឈុប កនណាវុឌ្ឍ** អនុប្រធាននាយកដ្ឋាន ផែនការវិនិយោគ

១៤-លោក **ថេង បញ្ញាជន** អនុប្រធាននាយកដ្ឋាន ទំនាក់ទំនងអន្តរជាតិ

១៥-លោក **គូ ដាលី** អនុប្រធាននាយកដ្ឋានបុគ្គលិក

១៦-លោក **ហាវ ឌីណា** អនុប្រធាននាយកដ្ឋានផ្គត់ផ្គង់ និងហិរញ្ញវត្ថុ

១៧-លោក **ផាំង ឈាងអាន** អនុប្រធាននាយកដ្ឋានផែនការសេដ្ឋកិច្ច

១៨-លោក **ស៊ុន ហ៊ន** ប្រធានការិយាល័យសរុប

១៩-លោក **ចិន ញាណរិទ្ធិ** ប្រធានការិយាល័យរដ្ឋបាលនៃនាយកដ្ឋានផែនការទូទៅ

២០-លោកស្រី **ធី វុឌ្ឍី** ប្រធានការិយាល័យផែនការទូទៅ

២១-លោក **ឈាង ម៉ាន់ថា** ប្រធានការិយាល័យអភិវឌ្ឍន៍ជនបទ

២២-លោក **តាំង លាងអ៊ី** ប្រធានការិយាល័យហេដ្ឋារចនាសម្ព័ន្ធ

២៣-លោក **ប៉េង គៀនសាយ** ប្រធានការិយាល័យពាណិជ្ជកម្មនិង ទេសចរណ៍

២៤-លោក **កែវ អ៊ូលី** ប្រធានការិយាល័យអាហារូបត្ថម្ភ

២៥-លោកស្រី **ឡុង ហំ្វរសេរី** ប្រធានការិយាល័យផែនការសង្គមកិច្ច

២៦-លោក **ជីង រដ្ឋា** ប្រធានការិយាល័យពហុភាគី

២៧-លោក **រ៉ុន នាង** ប្រធានការិយាល័យគណនេយ្យ

២៨-លោក **ហ៊ន ឌិន** ប្រធានការិយាល័យវិនិយោគសេដ្ឋកិច្ច

២៩-កញ្ញា **ថុ ចំណាន** ប្រធានការិយាល័យវិភាគព្យាករណ៍ស្ថានភាពវិនិយោគ

៣០-លោក **ឈួន សុធី** ប្រធានការិយាល័យកែឆ្នៃទិន្នន័យ

៣១-លោកស្រី **គី ប្ញូរ៉ែត** ប្រធានការិយាល័យវិភាគស្ថិតិសង្គមកិច្ច

៣២-លោក លឹម ពេញ ប្រធានការិយាល័យស្ថិតិប្រជាជន

៣៣-លោក ទឹម តីយ៉ារី ប្រធានការិយាល័យជំរឿន

៣៤-លោក ពាវ សាវី ប្រធានការិយាល័យអប់រំសិក្សានៃមជ្ឈមណ្ឌលបណ្តុះបណ្តាលផែនការ ស្ថិតិ

៣៥-លោក នុត សុខសៅរឿន ប្រធានការិយាល័យ

៣៦-លោក ស៊ឹម លី ប្រធានការិយាល័យសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់

៣៧-លោក យ៉ាន់ គង់ អនុប្រធានការិយាល័យពិធីការ

៣៨-លោក ហាន ដារិន អនុប្រធានការិយាល័យសរុប

៣៩-លោកស្រី ម៉ម បូណា អនុប្រធានការិយាល័យស្ថិតិពត៌មាន

៤០-លោក ជា អមរិន្ទ អនុប្រធានការិយាល័យសំភារៈ

៤១-កញ្ញា ឱុយ ស៊ុនណារី មន្ត្រីការិយាល័យពត៌មាននិងគំរោងទិន្នន័យ

៤២-លោក ហុក ធី អនុប្រធានការិយាល័យវិភាគស្ថិតិសង្គមកិច្ច

៤៣-កញ្ញា ខៀវ ម៉ារាវី អនុប្រធានការិយាល័យសង្គមកិច្ចនិងស្ថិតិការងារ

៤៤-លោក ស៊ិន សេរីវុឌ្ឍ អនុប្រធានការិយាល័យស្ថិតិពត៌មាន

៤៥-លោក អ៊ុន ចន្ធី មន្ត្រីការិយាល័យសំភារៈ

៤៦-លោក កែម វិបុល ប្រធានការិយាល័យបុគ្គលិក

៤៧-លោក ប៊ុន សុផល អនុប្រធានការិយាលយ័បៀវត្ស

៤៨-លោក មិន ធី អនុប្រធានការិយាល័យបណ្តុះបណ្តាល

៤៩ លោក ភាំង ឈុង អនុប្រធានការិយាល័យ

៥០- លោកស្រី ជា ចន្ទតារា អនុប្រធានការិយាល័យគណនេយ្យ

**មាត្រា ២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងផែនការ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ✓

រាជធានីភ្នំពេញ , ថ្ងៃទី២៨ ខែ ៧ ឆ្នាំ ២០០៣

ហ៊ុន សែន

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និង មាត្រា២
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៦០ ស.សរ

## សេចក្តីសំរេច

## ស្តីពីការផ្ទេរសិទ្ធ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្រលេខ នស / រកត ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

**ប្រការ ១ :** ត្រូវបានផ្ទេរសិទ្ធិជូនឯកឧត្តម **ស៊ុយ សែម** រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ជារដ្ឋមន្ត្រីស្តីទីក្រសួងពាណិជ្ជកម្ម ជំនួសឯកឧត្តម **ចម ប្រសិទ្ធ** ដែលត្រូវអញ្ជើញទៅបំពេញបេសកកម្ម នៅបរទេស ចាប់ពីថ្ងៃទី ០៦ រហូតដល់ថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០០៣ ។

**ប្រការ ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នប្រតិភូរាជរដ្ឋាភិបាល អភិបាលខេត្ត-ក្រុង និង ឯកឧត្តម **ស៊ុយ សែម** ត្រូវអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**<u>កន្លែងទទួល</u>**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ ២ ( ដើម្បីអនុវត្ត )
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខ:...៦១ សសរ......

**សេចក្តីសម្រេច**

**ស្តីពី**

**ការបង្កើតគណៈកម្មការទាក់ទងជាមួយសមភាគីថៃ និងដោះស្រាយ**
**ការងារពាក់ព័ន្ធនឹងការអនុវត្តលើគំរោងសាងសង់ផ្លូវជាតិលេខ ៦៧**
**(ច្រកសាងាំ អន្លង់វែង សៀមរាប )**

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-តាមស្មារតីនៃអង្គប្រជុំគណៈរដ្ឋមន្ត្រីចំរុះ កម្ពុជា-ថៃ នៅខេត្តសៀមរាប និង ខេត្តឧប៊ុនរាជធានី កាលពីថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០៣

-យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

**សំរេច**

**ប្រការ១** : បង្កើតគណៈកម្មការទាក់ទងជាមួយសមភាគីថៃ និងដោះស្រាយការងារពាក់ព័ន្ធនឹងការអនុវត្តលើគំរោងសាងសង់ផ្លូវជាតិលេខ ៦៧ (ច្រកសាងាំ អន្លង់វែង សៀមរាប) ដែលមានសមាសភាពដូចខាងក្រោម :-

| | | | |
|---|---|---|---|
| ១-ឯកឧត្តម **ត្រាំ អ៊ីវតឹក** | រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន | ប្រធាន |
| ២-ឯកឧត្តម **អ៊ុក ចាន់** | អនុរដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន | អនុប្រធាន |
| ៣-ឯកឧត្តម **វ៉ា គឹមហុង** | ប្រធានគណៈកម្មាធិការចំរុះ កិច្ចការព្រំដែន | សមាជិក |

៤-ឯកឧត្តម **ញាណ ឡេង** អនុរដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក

៥-ឯកឧត្តម **រស់ មូរ៉ាត** អគ្គនាយករង នៃអាជ្ញាធរអប្សរា សមាជិក

៦-ឯកឧត្តម **អ៊ុង អឿង** អភិបាលរងទី១ ខេត្តសៀមរាប សមាជិក

៧-ឯកឧត្តម **ម៉ៅ នឹម** អភិបាលរងទី១ ខេត្តឧត្ដរមានជ័យ សមាជិក

៨-លោក **ឡេង សុជា** អគ្គលេខាធិការរងនៃអាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន សមាជិក

៩-លោក **ឃុយ ហៀង** ប្រធាននាយកដ្ឋានគមនាគមន៍ និងប្រៃសណីយ៍ ទីស្ដីការគណៈរដ្ឋមន្ត្រី សមាជិក

១០-លោក **ចាន់ សុធី** ប្រធាននាយកដ្ឋានវិនិយោគ និងសហប្រតិបត្តិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក

១១-លោក **ទី សុគន្ធ** ប្រធាននាយកដ្ឋានរុក្ខាប្រមាញ់ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សមាជិក

១២-លោក **នា ជុប** ប្រធាននាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ក្រសួងបរិស្ថាន សមាជិក

១៣-លោក **លឹម ស៊ីដេនីន** ប្រធាននាយកដ្ឋានផ្លូវថ្នល់ ក្រសួងសាធារណការ និងដឹកជញ្ជូន សមាជិក

**ប្រការ២** : គណៈកម្មការនេះមានភារកិច្ចធ្វើទំនាក់ទំនង សហការជាមួយសមភាគីថៃ និងដោះស្រាយរាល់ការងារ ដែលពាក់ព័ន្ធនឹងការអនុវត្តលើគំរោងសាងសង់ផ្លូវជាតិលេខ៦៧ ( ច្រកសាងាំ អន្លង់វែង សៀមរាប ) និងធ្វើរបាយការណ៍អំពីលទ្ធផលការងារតាមរយៈទីស្ដីការគណៈរដ្ឋមន្ត្រីជូនប្រមុខរាជរដ្ឋាភិបាល ។

**ប្រការ៣** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ អភិបាលខេត្តសៀមរាប អភិបាលខេត្តឧត្ដរមានជ័យ និងសាមីខ្លួន ដែលមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្ដីសំរេចនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០០៣*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

កន្លែងទទួលៈ
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ដូចប្រការ ៣
- ឯកសារ- កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ០៧ សរ

# សារាចរ
## ស្តីពី
## ការគ្រប់គ្រង និងការប្រើប្រាស់ត្រា
## នៅតាមក្រសួង-ស្ថាប័ន

កន្លងមក រាជរដ្ឋាភិបាល បានសង្កេតឃើញថា ក្រសួង-ស្ថាប័ន បានដំណើរការយ៉ាងសកម្មក្នុងការចូលរួមអនុវត្តកម្មវិធីនយោបាយ របស់រាជរដ្ឋាភិបាល ដោយសំរេចបានលទ្ធផលជាផ្លែផ្កា គួរជាទីមោទនៈ ។ ប៉ុន្តែ រយៈពេលចុងក្រោយនេះ បន្ទាប់ពីការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រនីតិកាលទី៣ នាថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០៣មក រាជរដ្ឋាភិបាល ក៏បានពិនិត្យឃើញថា ដំណើរការខាងលើ ពិសេសការប្រើប្រាស់ត្រារបស់ក្រសួង-ស្ថាប័នមួយចំនួន មានការរអាក់រអួល ដែលជះឥទ្ធិពលអវិជ្ជមានដល់យន្តការគ្រប់គ្រង និងចាត់ចែងការងាររដ្ឋបាលសាធារណៈប្រចាំថ្ងៃ បណ្តាលមកពីប្រធានស្ថាប័នមួយចំនួន បានយកតាមខ្លួននូវត្រារបស់ក្រសួង-ស្ថាប័ន ទៅជាមួយ ។

ដើម្បីពង្រឹង និងធានាបាននិរន្តរភាពការងាររដ្ឋបាលសាធារណៈ នៅតាមក្រសួង-ស្ថាប័ន ក៏ដូចជាការអនុវត្តតាមស្មារតី នៃអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន រាជរដ្ឋាភិបាលសូមធ្វើការណែនាំ និងដាក់បញ្ជាដល់សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ នៃក្រសួង-ស្ថាប័ន ត្រូវប្រគល់ត្រាទៅឱ្យអគ្គនាយកដ្ឋានរដ្ឋបាល ឬ នាយកដ្ឋានរដ្ឋបាល សំរាប់គ្រប់គ្រង និងប្រើប្រាស់លើរាល់លិខិតបទដ្ឋាន និងលិខិតកិច្ចការរដ្ឋបាល ផ្សេងៗទៀត របស់ក្រសួង-ស្ថាប័ន ចាប់ពីថ្ងៃនេះតទៅ ។

ទទួលបានសារាចរនេះ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ នៃក្រសួង-ស្ថាប័ន ត្រូវអនុវត្តតាមខ្លឹមសារខាងលើ ឱ្យបានសំរេចលទ្ធផលជាវិជ្ជមាន ។

រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ សីហា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**ចម្លងជូន**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ក្រសួង រដ្ឋលេខាធិការដ្ឋាន និងស្ថាប័ន
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-គ្រប់សាលាខេត្ត-ក្រុង
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៧ សរណន

## សារាចរណែនាំ

## ស្តីពី

## ការប្រារព្ធទិវាអក្ខរកម្មជាតិ ៨ កញ្ញា

អនុវត្តតាមផែនការជាតិនៃការអប់រំ សំរាប់ទាំងអស់គ្នា ដែលប្រកាសផ្សព្វផ្សាយអនុវត្ត នាថ្ងៃ ទី ១០ មិថុនា ឆ្នាំ ២០០៣ ស្របតាមទសវត្សសហប្រជាជាតិ សំរាប់អក្ខរកម្ម និងតាមស្មារតីនៃព្រះរាជក្រឹត្យ លេខ នស.រកត ០៩០០ /១៦៣ ចុះថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការកំណត់យកថ្ងៃទី ៨ ខែ កញ្ញា រៀងរាល់ឆ្នាំ ជាទិវាអក្ខរកម្មជាតិនោះ រាជរដ្ឋាភិបាលកម្ពុជា ចេញសេចក្តីណែនាំដល់គ្រប់ក្រសួង ស្ថាប័ន ខេត្ត-ក្រុង អោយរៀបចំប្រារព្ធទិវាអក្ខរកម្មជាតិ ថ្ងៃទី ៨ ខែ កញ្ញា ឆ្នាំ២០០៣ ក្រោមប្រធានបទ " **អក្ខរកម្ម និងសន្តិភាព** " ដែលមានខ្លឹមសារណែនាំដូចខាងក្រោម :

១-ក្រសួងអប់រំ យុវជន និងកីឡា សហការជាមួយអាជ្ញាធររាជធានីភ្នំពេញ រៀបចំមិទ្ទិញថ្នាក់ជាតិ នៅថ្ងៃ ទី ៨ ខែ កញ្ញា ឆ្នាំ ២០០៣ ដើម្បីផ្សព្វផ្សាយលទ្ធផលអក្ខរកម្មនាឆ្នាំកន្លងមក និងប្រកាសអំពីផែនការយុទ្ធសាស្ត្រសំខាន់ៗនៃការអប់រំក្រៅប្រព័ន្ធដែលត្រូវអនុវត្តនាពេលខាងមុខ ដោយមានការចូលរួមពី មន្ទីរ ស្ថាប័ន អាជ្ញាធរ ដែនដីគ្រប់លំដាប់ថ្នាក់ អង្គការជាតិ និងអន្តរជាតិ សិស្ស និស្សិត និងប្រជាពលរដ្ឋ ។

២-អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ត្រូវចាត់ចែងរៀបចំ :

ក-បិទបដា ពាក្យស្លោក នៅតាមអង្គភាពរដ្ឋ ទីប្រជុំជន ដងផ្លូវសាធារណៈ ចាប់ពីថ្ងៃទី ៧ ដល់ថ្ងៃទី ៩ ខែ កញ្ញា ឆ្នាំ ២០០៣។

ខ-ធ្វើមិទ្ទិញ ឬប្រជុំហែរក្បួនដែលមានខ្លឹមសារពាក់ព័ន្ធទៅនឹងការបំផុសចលនាអក្ខរកម្ម និងសន្តិភាពល្អ។

គ-ត្រូវរៀបចំបំផុសចលនា និងធ្វើការប្រលងសិស្សអក្ខរកម្មតាមប្រធានបទ " **អក្ខរកម្ម និងសន្តិភាព** " តាមលក្ខខ័ណ្ឌដូចខាងក្រោម :

- ចំពោះទីកន្លែងដែលមានថ្នាក់រៀនអក្ខរកម្ម ត្រូវចាត់ចែងប្រលងសិស្សអក្ខរកម្ម ដើម្បីស្វែងយល់ពីសន្តិភាព បំបាត់នូវអំពើហិង្សាគ្រប់បែបយ៉ាង ហើយបេក្ខជនដែលទទួលបានពិន្ទុល្អក្នុងការប្រលងត្រូវចាត់ចែង ជូនរង្វាន់លើកទឹកចិត្តតាមការជាក់ស្តែង ។

- ចំពោះទីកន្លែង ដែលពុំមានថ្នាក់រៀនអក្ខរកម្ម ត្រូវចាត់ចែងមន្ត្រីជំនាញអោយចុះឃោសនាអំពីសារៈសំខាន់នៃការរៀនសូត្រ និងគ្រោះថ្នាក់នៃការមិនមានសន្តិភាព។

៣-ក្រសួងធម្មការ និងសាសនា ត្រូវណែនាំដល់ព្រះសង្ឃ គណៈកម្មការវត្តគ្រប់ជាន់ថ្នាក់ និងពុទ្ធបរិស័ទអោយមានសទ្ធាជ្រះថ្លាក្នុងការជួយឧបត្ថម្ភដល់ការងារអក្ខរកម្ម និងពន្យល់ណែនាំដល់ប្រជាជនអោយយល់អំពីសារៈសំខាន់នៃការរៀនសូត្រ និងរក្សាសន្តិភាព ទាំងផ្លូវចិត្ត ទាំងផ្លូវកាយ បំបាត់នូវអំពើហិង្សាគ្រប់រូបភាព ដើម្បីជនកម្ពុជារស់នៅដោយសុខកាយសប្បាយចិត្ត។

៤-ក្រសួងពត៌មាន និងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ត្រូវពិនិត្យលទ្ធភាពរៀបចំសំដែងសិល្បៈ បទអត្ថាធិប្បាយ បទយកការណ៍ ស្តីពីការងារ អប់រំក្រៅប្រព័ន្ធនៅកម្ពុជា ផ្សព្វផ្សាយតាមវិទ្យុ និងទូរទស្សន៍។

៥-អង្គការអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាលនានា និងសប្បុរសជនសូមជួយឧបត្ថម្ភ ដល់ពិធីបុណ្យនេះនៅតាមទីកន្លែង និងតាមលទ្ធភាព។

៦-គណៈកម្មាធិការអប់រំសំរាប់ទាំងអស់គ្នានៅគ្រប់លំដាប់ថ្នាក់ ត្រូវប្រជុំសិក្សារៀនសូត្រអំពីគោលនយោបាយនៃការងារអប់រំក្រៅប្រព័ន្ធ និងផែនការជាតិអប់រំសំរាប់ទាំងអស់គ្នា ព្រមទាំងបូកសរុបលទ្ធផលនៃការងារអប់រំក្រៅប្រព័ន្ធអោយបានជាក់ស្តែងតាមឋានានុក្រមនីមួយៗ។

ទទួលបានសារាចរណែនាំនេះ សូមឯកឧត្តម លោកជំទាវ លោក លោកស្រី ថ្នាក់ដឹកនាំគ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ អភិបាលខេត្ត-ក្រុង គណៈកម្មាធិការជាតិអប់រំសំរាប់ទាំងអស់គ្នា ផ្សព្វផ្សាយ និងរៀបចំណែនាំ ព្រមទាំងអនុវត្តសារាចរនេះអោយទទួលបានលទ្ធផលល្អប្រសើរ រួចហើយត្រូវធ្វើរបាយការណ៍ស្តីពីលទ្ធផលនៃការរៀបចំពិធីនេះ ផ្ញើមកក្រសួងអប់រំ យុវជន និងកីឡា ដើម្បីបូកសរុបជូន គណៈរដ្ឋមន្ត្រី អោយបានមុនដំណាច់ខែ កញ្ញា ឆ្នាំ ២០០៣។

រាជធានីភ្នំពេញ, ថ្ងៃទី២១ ខែ សីហា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**<u>កន្លែងទទួល</u>**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
" ដើម្បីទូលថ្វាយ និងគោរពជូនជ្រាបជាពត៌មាន"
-គ្រប់ក្រសួង ស្ថាប័ននានា
-គ្រប់អភិបាលខេត្ត-ក្រុង
" ដើម្បីអនុវត្ត"
-កាលប្បវត្តិ-ឯកសារ

# ពាក្យស្លោក

១. ជាតិ សាសនា ព្រះមហាក្សត្រ

២. ជយោ ព្រះរាជាណាចក្រកម្ពុជា

៣. អបអរសាទរទិវាអក្ខរកម្មជាតិ ៨ កញ្ញា

៤. រៀនហើយ រៀនទៀត រៀនពេញមួយជីវិត

៥. អប់រំសំរាប់ទាំងអស់គ្នា ទាំងអស់គ្នាដើម្បីអប់រំ

៦. រៀនដើម្បីអភិវឌ្ឍន៍ខ្លួនឯង និងសង្គមជាតិ

៧. មានសន្តិភាព មានការអភិវឌ្ឍន៍

៨. សន្តិភាព និងអក្ខរកម្ម គឺ ជាគន្លឹះនៃការអភិវឌ្ឍន៍

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

លេខ : ២៨៧ បទ.ប្រក.

រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែ សីហា ឆ្នាំ២០០៣

## ប្រកាស

## ស្តីអំពីការគ្រប់គ្រងបរិក្ខារវិទ្យុគមនាគមន៍ និង ថ្លៃប្រើប្រាស់រលកអាកាសវិទ្យុ

### រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ០៥ អនក្រ ចុះថ្ងៃទី០៥-០៣-៨៧ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ស្តីអំពីប្រៃសណីយ៍ និង ទូរគមនាគន៍
- បានឃើញអនុក្រឹត្យលេខ ៦៦ អនក្រ/បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ៨៦ អនក្រ/បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០០២ ស្តីពីការកែសំរួល និងបំពេញបន្ថែមនាយកដ្ឋានមួយចំនួននៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ០៥ អនក្រ/បក ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០០៣ ស្តីពីការតម្លើងនាយកដ្ឋានរដ្ឋបាលនិងបណ្តុះបណ្តាល ទៅជាអគ្គនាយកដ្ឋានរដ្ឋបាល នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញសេចក្តីសំរេចលេខ ១៥៤ សសរ ចុះថ្ងៃទី១១-១២-៩១ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ស្តីពីឋានានុក្រមគ្រប់គ្រងតម្លៃ

កាច់ជ្រុងវិថីលេខ ១៣ និង ១០២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ
ទូរស័ព្ទ: (៨៥៥) ២៣-៧២៥៩១០/៤២៦៥១០
ទូរសារ: (៨៥៥) ២៣-៤២៦៩៩២/៤២៦០១១

- យោងស្មារតីអង្គប្រជុំរបស់គណៈកម្មាធិការផែនការ ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ នាថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ២០០២ និងអង្គប្រជុំ ថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ២០០៣ ស្តីពីការគ្រប់គ្រងបរិក្ខាវិទ្យុគមនាគមន៍ និង ការកែប្រែតម្លៃប្រើប្រាស់រលកអាកាសវិទ្យុ សំរាប់ឆ្នាំ២០០៣ ដែលរៀបចំស្នើឡើងដោយក្រុមការងារ តំណាងអង្គភាពជំនាញ ។

## សំរេច

ប្រការ១ : កំណត់គោលការប្រើប្រាស់សេវាបរិក្ខារវិទ្យុគមនាគមន៍ ដូចមានឧបសម្ព័ន្ធទី១ ដល់ឧបសម្ព័ន្ធទី៣ភ្ជាប់នឹងសេចក្តីប្រកាសនេះ ។

ប្រការ២ : ប្រកាសស្តីពីការគ្រប់គ្រងបរិក្ខារវិទ្យុគមនាគមន៍និងថ្លៃប្រើប្រាស់រលកអាកាសវិទ្យុ លេខ ៨០ បទ.ប្រក ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០០២ និងរួមទាំងប្រកាសទាំងឡាយណាដែលមានពីមុន ហើយមានន័យផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ៣ : អគ្គនាយកដ្ឋានរដ្ឋបាល អគ្គនាយកដ្ឋានប្រៃសណីយ៍ និង ទូរគមនាគមន៍ ខុទ្ទកាល័យ អធិការដ្ឋាន គ្រប់នាយកដ្ឋានពាក់ព័ន្ធ និងគ្រប់មន្ទីរប្រៃសណីយ៍ និង ទូរគមនាគមន៍ ខេត្ត -ក្រុងក្រោមឱវាទ ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ ត្រូវទទួលបន្ទុកអនុវត្តតាមតួនាទី ភារកិច្ចនូវប្រកាសនេះ ឱ្យមានប្រសិទ្ធិភាពខ្ពស់ ។

ប្រការ៤ : ប្រកាសនេះចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រដ្ឋមន្ត្រី

សូរ-ឃុន

**កន្លែងទទួល**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- រាជកិច្ច
- ក្រសួងផែនការ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
  " ដើម្បីជ្រាបជាពត៌មាន "
- ដូចប្រការ៣ " ដើម្បីអនុវត្ត "
- ឯកសារ - កាលប្បវត្តិ

ឧបសម្ព័ន្ធភ្ជាប់ប្រកាសលេខ : ២៧២ បទ.ប្រក ចុះថ្ងៃទី ១៥ ខែ សីហា ឆ្នាំ២០០៣

**ចាប់អនុវត្តន៍ពីថ្ងៃទី ១៥ ខែ សីហា ឆ្នាំ២០០៣**

**ឧបសម្ព័ន្ធទី១**

**ថ្លៃប្រើប្រាស់រលកអាកាសវិទ្យុ**

១- វិទ្យុប្រភេទ MF — រៀល

ក/វិទ្យុប្រភេទ MF ចល័ត

| | |
|---|---|
| - ការទទួលពិនិត្យពាក្យសុំប្រើប្រាស់ឋបនភ័ណ្ឌមួយគ្រឿង១ | ១០.០០០ |
| - ការពិនិត្យឋបនភ័ណ្ឌមួយគ្រឿង១ មុនពេលតំលើងលើនាវា | ៣០.០០០ |
| - ការពិនិត្យឋបនភ័ណ្ឌមួយគ្រឿង១ មុនពេលតំលើងលើដីគោក | ២៥.០០០ |
| - តម្លៃអាជ្ញាប័ណ្ណប្រចាំឆ្នាំ សម្រាប់ឋបនភ័ណ្ឌមួយគ្រឿង១ ចំពោះអានុភាព X watt និង បន្ទារហ្វ្រេកង់ Y KHz | ៧០.០០០+៣.០០០X+៧.០០០Y |

ខ/វិទ្យុប្រភេទ MF អចល័ត

| | |
|---|---|
| - ការទទួលពិនិត្យពាក្យសុំប្រើប្រាស់ឋបនភ័ណ្ឌមួយគ្រឿង១ | ១០.០០០ |
| - ការពិនិត្យឋបនភ័ណ្ឌមួយគ្រឿង១ មុនពេលតំលើង | ២៥.០០០ |
| - តម្លៃអាជ្ញាប័ណ្ណប្រចាំឆ្នាំ សម្រាប់ឋបនភ័ណ្ឌមួយគ្រឿង១ ចំពោះអានុភាព X watt និង បន្ទារហ្វ្រេកង់ Y KHz | ៧០.០០០+២.០០០X+៧.០០០Y |

២- វិទ្យុប្រភេទ HF (PTT : Push To Talk) — រៀល

*សំគាល់:* ចំពោះស្ថានទូតក្នុងការទាក់ទងផ្ទាល់ជាមួយប្រទេសរបស់ខ្លួន ត្រូវបានអនុគ្រោះមិនគិតតម្លៃអាជ្ញាប័ណ្ណ ។

ក/វិទ្យុប្រភេទ HF ចល័ត

| | |
|---|---|
| - ការទទួលពិនិត្យពាក្យសុំប្រើប្រាស់ឋបនភ័ណ្ឌមួយគ្រឿង១ | ១០.០០០ |
| - ការពិនិត្យឋបនភ័ណ្ឌមួយគ្រឿង១ មុនពេលតំលើងលើនាវា | ៣០.០០០ |
| - កាពិនិត្យឋបនភ័មួយគ្រឿង១ មុនពេលតំលើងលើដីគោក | ២៥.០០០ |
| - តម្លៃអាជ្ញាប័ណ្ណប្រចាំឆ្នាំ សម្រាប់ឋបនភ័ណ្ឌមួយគ្រឿង១ ចំពោះអានុភាព X watt និង បន្ទារហ្វ្រេកង់ Y KHz | ៧០.០០០+៣.០០០X +៧.០០០Y |

ឧបសម្ព័ន្ធភ្ជាប់ប្រកាសលេខ : ២៧២ បទ.ប្រក ចុះថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០០៣

ខ/វិទ្យុប្រភេទ HF អចល័ត

- ការទទួលពិនិត្យពាក្យសុំប្រើប្រាស់បរិក្ខារមួយគ្រឿងៗ ១០,០០០
- ការពិនិត្យបរិក្ខារមួយគ្រឿងៗ មុនពេលតំលើង ២៥,០០០
- តម្លៃអាជ្ញាប័ណ្ណប្រចាំឆ្នាំ សម្រាប់បរិក្ខារមួយគ្រឿងៗ

ចំពោះអានុភាព X watt និង បន្ទារប្រេកង់ Y KHz ៧០,០០០+១,៥០០X+៧,០០០Y

៣- វិទ្យុប្រភេទ VHF (PTT : Push To Talk) រៀល

ក/វិទ្យុប្រភេទ VHF ចល័តទូទាំងក្នុងផ្ទៃប្រទេស

- ការទទួលពិនិត្យពាក្យសុំប្រើប្រាស់បរិក្ខារមួយគ្រឿងៗ ១០,០០០
- ការពិនិត្យបរិក្ខារមួយគ្រឿងៗ មុនពេលតំលើង :
  - ចំពោះវិទ្យុទាក់ទងតូចៗកាន់ជាប់នឹងដៃ (walkie talkie) ១០,០០០
  - ចំពោះវិទ្យុទាក់ទងធម្មតាពុំមែនកាន់ជាប់នឹងដៃនៅលើនាវា ២០,០០០
  - ចំពោះវិទ្យុទាក់ទងធម្មតាពុំមែនកាន់ជាប់នឹងដៃនៅលើដី ១៥,០០០
- តម្លៃអាជ្ញាប័ណ្ណប្រចាំឆ្នាំ សម្រាប់បរិក្ខារមួយគ្រឿងៗ

ចំពោះអានុភាព X watt និង បន្ទារប្រេកង់ Y KHz ៣០,០០០+១,៨០០X+៨០០Y

ខ/វិទ្យុប្រភេទ VHF ចល័តក្នុងខេត្ត/ក្រុង

- ការទទួលពិនិត្យពាក្យសុំប្រើប្រាស់បរិក្ខារមួយគ្រឿងៗ ១០,០០០
- ការពិនិត្យបរិក្ខារមួយគ្រឿងៗ មុនពេលតំលើង :
  - ចំពោះវិទ្យុទាក់ទងតូចៗកាន់ជាប់នឹងដៃ (walkie talkie) ១០,០០០
  - ចំពោះវិទ្យុទាក់ទងធម្មតាពុំមែនកាន់ជាប់នឹងដៃនៅលើនាវា ២០,០០០
  - ចំពោះវិទ្យុទាក់ទងធម្មតាពុំមែនកាន់ជាប់នឹងដៃនៅលើដី ១៥,០០០
- តម្លៃអាជ្ញាប័ណ្ណប្រចាំឆ្នាំ សម្រាប់បរិក្ខារមួយគ្រឿងៗ

ចំពោះអានុភាព X watt និង បន្ទារប្រេកង់ Y KHz ៣០,០០០+១,៥០០X+៨០០Y

គ/វិទ្យុប្រភេទ VHF អចល័ត

- ការទទួលពិនិត្យពាក្យសុំប្រើប្រាស់បរិក្ខារមួយគ្រឿងៗ ១០,០០០
- ការពិនិត្យបរិក្ខារមួយគ្រឿងៗ មុនពេលតំលើង ១៥,០០០
- តម្លៃអាជ្ញាប័ណ្ណប្រចាំឆ្នាំ សម្រាប់បរិក្ខារមួយគ្រឿងៗ

ចំពោះអានុភាព X wat និង បន្ទារប្រេកង់ Y KHz ៣០,០០០+១,០០០X+៨០០Y

ឧបសម្ព័ន្ធភ្ជាប់ប្រកាសលេខ : ៦៧៦ បទ.ប្រក ចុះថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០០៣

| | | |
|---|---|---|
| ៤- | **វិទ្យុប្រភេទ UHF** (PTT : Push To Talk) | រៀល |
| | **ក/វិទ្យុប្រភេទ UHF ចល័តទូទាំងក្នុងផ្ទៃប្រទេស** | |
| | - ការទទួលពិនិត្យពាក្យសុំប្រើប្រាស់បរិក្ខារមួយគ្រឿង១ | ១០,០០០ |
| | - ការពិនិត្យបរិក្ខារមួយគ្រឿង១ មុនពេលតំលើង : | |
| | ចំពោះវិទ្យុទាក់ទងតូច១កាន់ជាប់នឹងដៃ ( walkie talkie ) | ១០,០០០ |
| | ចំពោះវិទ្យុទាក់ទងធម្មតាពុំមែនកាន់ជាប់នឹងដៃនៅលើនាវា | ២០,០០០ |
| | ចំពោះវិទ្យុទាក់ទងធម្មតាពុំមែនកាន់ជាប់នឹងដៃនៅលើដី | ១៥,០០០ |
| | - តម្លៃអាជ្ញាប័ណ្ណប្រចាំឆ្នាំ សម្រាប់បរិក្ខារមួយគ្រឿង១ | |
| | ចំពោះអានុភាព X watt និង បន្ទារប្រេកង់ Y KHz | ៣០,០០០+១,៥០០X+៨០០Y |
| | **ខ/ វិទ្យុប្រភេទ UHF ចល័តក្នុងខេត្ត/ក្រុង** | |
| | - ការទទួលពិនិត្យពាក្យសុំប្រើប្រាស់បរិក្ខារមួយគ្រឿង១ | ១០,០០០ |
| | - ការពិនិត្យបរិក្ខារមួយ១ មុនពេលតំលើង : | |
| | ចំពោះវិទ្យុទាក់ទងតូច១កាន់ជាប់នឹងដៃ ( walkie talkie ) | ១០,០០០ |
| | ចំពោះវិទ្យុទាក់ទងធម្មតាពុំមែនកាន់ជាប់នឹងដៃនៅលើនាវា | ២០,០០០ |
| | ចំពោះវិទ្យុទាក់ទងធម្មតាពុំមែនកាន់ជាប់នឹងដៃនៅលើដី | ១៥,០០០ |
| | - តម្លៃអាជ្ញាប័ណ្ណប្រចាំឆ្នាំ សម្រាប់បរិក្ខារមួយគ្រឿង១ | |
| | ចំពោះអានុភាព X watt និង បន្ទារប្រេកង់ Y KHz | ៣០,០០០+១,៣០០X+៨០០Y |
| | **គ/វិទ្យុប្រភេទ UHF អចល័ត** | |
| | - ការទទួលពិនិត្យពាក្យសុំប្រើប្រាស់បរិក្ខារមួយគ្រឿង១ | ១០,០០០ |
| | - ការពិនិត្យបរិក្ខារមួយគ្រឿង១ មុនពេលតំលើង | ១០,០០០ |
| | - តម្លៃអាជ្ញាប័ណ្ណប្រចាំឆ្នាំ សម្រាប់បរិក្ខារមួយគ្រឿង១ | |
| | ចំពោះអានុភាព X watt និង បន្ទារប្រេកង់ Y KHz | ៣០,០០០+១,០០០X+៨០០Y |
| ៥- | **វិទ្យុប្រភេទ TLMRS, Paging, Mobile Cellular Phone, Wireless Fixed Phone** | $ |
| | *សំគាល់* ចំពោះបរិក្ខាតូច១ ឬ កាន់ជាប់នឹងដៃពុំចាំបាច់មានអាជ្ញាប័ណ្ណទេ ។ | |
| | - ការទទួលពិនិត្យពាក្យសុំដំណើរការ Base Station | ៥០ |
| | - ការពិនិត្យបរិក្ខារសំរាប់ Base Station | ១០០ |
| | - តម្លៃអាជ្ញាប័ណ្ណប្រចាំឆ្នាំ សម្រាប់ដំណើរការនៃប្រព័ន្ធទូទាំងប្រទេស | |
| | ចំពោះអានុភាព X watt និង បន្ទារប្រេកង់ Y KHz | ១០០ + ៣០X + ២.៥Y |

ឧបសម្ព័ន្ធភ្ជាប់ប្រកាសលេខ : ៦៧៦ បទ.ប្រក ចុះថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០០៣

៦- វិទ្យុគ្រប់ប្រភេទជាប្រព័ន្ធបញ្ជូនទិន្នន័យ រឺជា **Wireless Access Network** $

ក/ **ករណីសំរាប់ ISP**

- ការទទួលពិនិត្យពាក្យសុំដំណើរការ Base Station ៥០
- ការពិនិត្យឋបនភ័ណ្ឌសំរាប់ Base Station ១០០
- តម្លៃអាជ្ញាប័ណ្ណប្រចាំឆ្នាំ សម្រាប់ដំណើរការនៃប្រព័ន្ធទូទាំងប្រទេស

ចំពោះបន្ទារហ្វ្រេកង់ Y KHz ៥០០ + 0.២Y

( ចំពោះ Subscriber របស់ ISP ពុំចាំបាច់មានអាជ្ញាប័ណ្ណទេ )

ខ/ **ករណីធម្មតា**

- ការទទួលពិនិត្យពាក្យសុំប្រើប្រាស់ឋបនភ័ណ្ឌមួយគ្រឿង១ ៣០
- ការពិនិត្យឋបនភ័ណ្ឌមួយគ្រឿង១ មុនពេលតំលើង ៥០

ខ-១/ **ករណី Analoge**

- តម្លៃអាជ្ញាប័ណ្ណប្រចាំឆ្នាំ សម្រាប់ឋបនភ័ណ្ឌមួយគ្រឿង១

ចំពោះអានុភាព X watt និង បន្ទារហ្វ្រេកង់ Y KHz ៥០០ + ១.៨X + ១.២Y

ខ-២/ **ករណី Digital**

- តម្លៃអាជ្ញាប័ណ្ណប្រចាំឆ្នាំ សម្រាប់ឋបនភ័ណ្ឌមួយគ្រឿង១

ល្បឿនបញ្ជូនតូចជាង រឺ ស្មើ 128 Kbps ៣៥០

ល្បឿនបញ្ជូនធំជាង 128 Kbps រឺ ស្មើ 512 Kbps ៤០០

ល្បឿនបញ្ជូនធំជាង 512 Kbps រឺ ស្មើ 2 Mbps ៤៥០

ល្បឿនបញ្ជូនធំជាង 2 Mbps ៥០០

៧- វិទ្យុគ្រប់ប្រភេទជា **MICROWAVE** $

- ការទទួលពិនិត្យពាក្យសុំប្រើប្រាស់ឋបនភ័ណ្ឌមួយគ្រឿង១ ៣០
- ការពិនិត្យឋបនភ័ណ្ឌមួយគ្រឿង១ មុនពេលតំលើង ៥០
- តំលៃអាជ្ញាបណ្ណប្រចាំឆ្នាំ សម្រាប់ឋបនភ័ណ្ឌមួយគ្រឿង១ សំរាប់ល្បឿនបញ្ជូន:

ក/ **បង់ហ្វ្រេកង់ ពី ១.៥ GHz ទៅ ៦ GHz**

| | | | | |
|---|---|---|---|---|
| ចាប់ពី | ២Mbps | តែតូចជាង | ៨Mbps | ៥០០ |
| ចាប់ពី | ៨Mbps | តែតូចជាង | ៣៤Mbps | ៦០០ |
| ចាប់ពី | ៣៤Mbps | តែតូចជាង | ១៤០Mbps | ៨០០ |
| ចាប់ពី | ១៤០Mbps | លើងទៅ | | ១,០០០ |

ឧបសម្ព័ន្ធភ្ជាប់ប្រកាសលេខ : ៦៧៦ បទ.ប្រក ចុះថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០០៣

| | | | | |
|---|---|---|---|---|
| ខ/ បង់ប្រេកង់ | | ពី ៧ GHz | ទៅ ១៥ GHz | |
| ចាប់ពី | ២Mbps | តែតូចជាង | ៨Mbps | ៤៥០ |
| ចាប់ពី | ៨Mbps | តែតូចជាង | ៣៤Mbps | ៥៥០ |
| ចាប់ពី | ៣៤Mbps | តែតូចជាង | ១៤០Mbps | ៧០០ |
| ចាប់ពី | ១៤០Mbps | លើងទៅ | | ៨៥០ |
| គ/ បង់ប្រេកង់ | | លើសពី ១៥ GHz លើងទៅ | | |
| ចាប់ពី | ២Mbps | តែតូចជាង | ៨Mbps | ៤០០ |
| ចាប់ពី | ៨Mbps | តែតូចជាង | ៣៤Mbps | ៥០០ |
| ចាប់ពី | ៣៤Mbps | តែតូចជាង | ១៤០Mbps | ៦០០ |
| លើសពី | ១៤០Mbps | លើងទៅ | | ៧០០ |

| | | |
|---|---|---|
| ៨- | បរិក្ខាទំនាក់ទំនងអន្តរជាតិ ( ក្នុងករណីមានការអនុញ្ញាតិពិសេស) | $ |
| | ក/ វិទ្យុទាក់ទងអន្តរជាតិ ( PTT : Push To Talk ) | |
| | - ការទទួលពិនិត្យពាក្យសុំប្រើប្រាស់បរិក្ខានិមួយៗ | ១០ |
| | - ការបិនិត្យបនភ័ណ្ឌមួយគ្រឿងៗ មុនពេលតំលើង | ២០ |
| | - តម្លៃអាជ្ញាប័ណ្ណប្រចាំឆ្នាំ សម្រាប់វិទ្យុមួយគ្រឿង | ២០ + ០.៨X + ២Y |
| | ខ/ VSAT សំរាប់សំលេង / ទិន្នលេខ | |
| | - ការទទួលពិនិត្យពាក្យសុំប្រើប្រាស់បរិក្ខានិមួយៗ | ៥០ |
| | - កាពិនិត្យបនភ័ណ្ឌមួយគ្រឿងៗ មុនពេលតំលើង | ១០០ |
| | - តម្លៃសួយសារប្រចាំខែ | ២,០០០ |
| | - តម្លៃអាជ្ញាប័ណ្ណប្រចាំឆ្នាំ សម្រាប់ស្ថានីយ៍មួយគ្រឿង | ៤,០០០ |
| | គ/ VSAT សំរាប់បញ្ជូនរូបភាពទូរទស្សន៍ ( Non-preemptible ) | |
| | - ការទទួលពិនិត្យពាក្យសុំប្រើប្រាស់បរិក្ខានិមួយៗ | ៥០ |
| | - ការពិនិត្យបនភ័ណ្ឌមួយគ្រឿងៗ មុនពេលតំលើង | ១០០ |
| | - តម្លៃអាជ្ញាប័ណ្ណប្រចាំថ្ងៃ សម្រាប់ស្ថានីយ៍មួយគ្រឿង | ២,០០០ |
| ៩- | វិទ្យុផ្សាយលំលេង | $ |
| | - ការទទួលពិនិត្យពាក្យសុំបើកស្ថានីយ៍និមួយៗ | ៣០ |
| | - ការពិនិត្យបនភ័ណ្ឌមួយគ្រឿងៗ មុនពេលតំលើង | ៥០ |

ឧបសម្ព័ន្ធភ្ជាប់ប្រកាសលេខ : ៦៧៦ បទ.ប្រក ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០០៣

ក/ តម្លៃអាជ្ញាប័ណ្ណប្រចាំឆ្នាំលើវិទ្យុប្រភេទ AM ; SW

ចំពោះអានុភាព X watt និង បន្ទារប្រេកង់ Y KHz ១០០ + 0.0៥X + ២0Y

ខ/ តម្លៃអាជ្ញាប័ណ្ណប្រចាំឆ្នាំលើវិទ្យុប្រភេទ FM

ចំពោះអានុភាព X watt និង បន្ទារប្រេកង់ Y KHz ១០០ + 0.0៥X + ២Y

## ១០- ទូរទស្សន៍ $

- ការទទួលពិនិត្យពាក្យសុំបើកស្ថានីយ៍និមួយៗ ៣0
- ការពិនិត្យថបនភ័ណ្ឌមួយគ្រឿងៗ មុនពេលតំលើង ៥0

ក/ តម្លៃអាជ្ញាប័ណ្ណប្រចាំឆ្នាំ ចំពោះទូរទស្សន៍ប្រភេទ VHF

ចំពោះអានុភាព X watt និង បន្ទារប្រេកង់ Y KHz ១០០ + 0.0៥X + 0.0៥Y

ខ/ តម្លៃអាជ្ញាប័ណ្ណប្រចាំឆ្នាំ ចំពោះទូរទស្សន៍ប្រភេទ UHF

ចំពោះអានុភាព X watt និង បន្ទារប្រេកង់ Y KHz ១០០ + 0.0៥X + 0.0៤Y

គ/ តម្លៃអាជ្ញាបណ្ណ័ប្រចាំឆ្នាំ ចំពោះទូរទស្សន៍ប្រភេទ MMDS

ចំពោះអានុភាព X watt និង បន្ទារប្រេកង់ Y KHz ១០០ + 0.0៥X + 0.0៣Y

## ១១- វិទ្យុអាម៉ាទ័រ $

- ការទទួលពិនិត្យពាក្យសុំប្រើប្រាស់ ៥
- ការពិនិត្យថបនភ័ណ្ឌមួយគ្រឿងៗ មុនពេលតំលើង ១0
- តម្លៃអាជ្ញាប័ណ្ណប្រចាំឆ្នាំ សម្រាប់ស្ថានីយ៍មួយគ្រឿង ២៥

## ១២- អ៊ិនម៉ាសាត **INMARSAT** $

ក/ អ៊ិនម៉ាសាតគ្រប់ប្រភេទចល័តឬអចល័ត ឬ តាំងជាប់នៅលើនាវា

១- ការទទួលពិនិត្យពាក្យសុំប្រើប្រាស់បរិក្ខានិមួយៗ ៣0

២- ការពិនិត្យថបនភ័ណ្ឌមួយគ្រឿងៗ មុនពេលតំលើង ១00

៣- តម្លៃអាជ្ញាប័ណ្ណប្រចាំឆ្នាំ ២00

៤- តម្លៃប្រើប្រាស់ស្មើនឹងតម្លៃរបស់ស្ថានីយ៍អ៊ិម៉ាសាតលើដី +១៥%

៥- ប្រាក់កក់សំរាប់ទូទាត់តម្លៃនៃការប្រើប្រាស់អ៊ិនម៉ាសាត១គ្រឿង ១,000

ឧបសម្ព័ន្ធភ្ជាប់ប្រកាសលេខ : ៦៧២ បទ.ប្រក ចុះថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០០៣

ចំពោះអ៊ិនម៉ាសាតតាំងជាប់នៅលើនាវា អតិថិជនអាចមិនជ្រើសរើសយកក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ធ្វើជាអាជ្ញាធរទូទាត់ ( Accounting Authority ) សំរាប់ទូទាត់តម្លៃជាមួយស្ថានីយ៍អ៊ិនម៉ាសាតលើដី ។ ក្នុងករណីនេះចំនុច ៤និង៥មិនគិតទេ ។

**ខ/ ចំពោះអ៊ិនម៉ាសាតគ្រប់ប្រភេទ ដែលចុះឈ្មោះនៅបរទេសហើយនាំចូល**

| | |
|---|---|
| មកប្រើប្រាស់នៅលើទឹកដីរបស់ព្រះរាជាណាចក្រកម្ពុជា | $ |
| - ការទទួលពិនិត្យពាក្យសុំប្រើប្រាស់បរិក្ខានិមួយៗ | ៣០ |
| - ការពិនិត្យឋបនភ័ណ្ឌមួយគ្រឿងៗ មុនពេលតំលើង | ៥០ |
| - តម្លៃអាជ្ញាប័ណ្ណប្រចាំឆ្នាំ | ៤០០ |

## ១៣- ល័ក្ខខ័ណ្ឌនៃការផ្គត់ផ្គង់សេវា

ក្រសួងប.ទជំរុញការអភិវឌ្ឍន៏ និងការប្រើប្រាស់ប្រព័ន្ធទូរគមនាគមន៍ដែលសមស្របតាមលក្ខណៈបច្ចេកទេស ។ ក្នុងករណីដែលប្រព័ន្ធទូរគមនាគមន៍ពុំទាន់មាន ក្រសួងប.ទបានអនុញ្ញាត្តិឱ្យមានការប្រើប្រាស់វិទ្យុគមនាគមន៍ ហើយបានកំណត់តម្លៃទាបសំរាប់ប្រេកង់នោះ ។ ប៉ុន្តែក្នុងករណីដែលប្រព័ន្ធបណ្តាញទូរគមនាគមន៍មានរួចហើយ តម្លៃរលកអាកាសវិទ្យុសេវានោះនឹងមានកំរិតមកជាធម្មតាវិញ ។ ដូច្នេះហើយតម្លៃរលកអាកាសវិទ្យុខាងលើនេះអាចមានកំរិតខ្ពស់ ឬទាប ទៅតាមករណីនីមួយៗ ។ ក្នុងករណីដែលអាចធ្វើអោយប៉ះពាល់ដល់ សេវានៃបណ្តាញទូរគមនាគមន៍ខ្លាំងពេក ក្រសួងប.ទអាចមិនអនុញ្ញាត្តិឱ្យប្រើប្រាស់ប្រព័ន្ធវិទ្យុគមនាគមន៍នោះ ។

១៣.១ ចំពោះអង្គការមនុស្សធម៌អន្តរជាតិ ឬ អង្គការមិនមែនរដ្ឋាភិបាល ដែលមានកិច្ចព្រមព្រៀងក្របខ័ណ្ឌក្នុងការអនុគ្រោះពន្ធ ទូទៅជាមួយព្រះរាជាណាចក្រកម្ពុជា គឺត្រូវបានអនុគ្រោះ៧០% នៃតម្លៃធម្មតាសំរាប់តម្លៃអាជ្ញាប័ណ្ណប្រចាំឆ្នាំ ។

១៣.២ ចំពោះ Two-Way Radios បន្ទារប្រេកង់នៃវិទ្យុមានពីរផ្នែកគឺផ្សាយនិងទទួល ។ ក្នុងករណីនេះការគិតតម្លៃប្រេកង់ គឺគិតតែមួយផ្នែកដែលជាបរិក្ខារផ្សាយ ។

១៣.៣ អានុភាពផ្សាយគិតតាមអានុភាពអតិបរិមានៃបរិក្ខារ ។

១៣.៤ រយៈពេលកំណត់នៃអាជ្ញាប័ណ្ណមានមួយឆមាស ឬ មួយឆ្នាំ ។ ក្នុងករណីអាជ្ញាប័ណ្ណមានរយៈពេលមួយឆមាស តម្លៃអាជ្ញាប័ណ្ណនោះស្មើនឹងពាក់កណ្តាលនៃតម្លៃអាជ្ញាប័ណ្ណប្រចាំឆ្នាំនៃបរិក្ខារនោះ ។

១៣.៥ ការសុំប្រើប្រាស់បន្តដោយគ្មានប្រការណាមួយប្រែប្រួលនៅក្នុងអាជ្ញាប័ណ្ណចាស់ គឺត្រូវគិតតែតម្លៃអាជ្ញាប័ណ្ណប្រចាំឆ្នាំ សំរាប់អាជ្ញាប័ណ្ណថ្មី ។

១៣.៦ អ្នកកោសលប់ ឬ ក្លែងបន្លំដោយប្រការណាមួយនៅលើអាជ្ញាប័ណ្ណ ត្រូវទទួលទោសតាមច្បាប់ជាធរមាន នៃព្រះរាជាណាចក្រកម្ពុជា ។

ឧបសម្ព័ន្ធភ្ជាប់ប្រកាសលេខ : ២៧២ បទ.ប្រក ចុះថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០០៣

**ចាប់អនុវត្តន៍ពីថ្ងៃទី ១៥ ខែ សីហា ឆ្នាំ២០០៣**

**ឧបសម្ព័ន្ធទី២**

**ការទទួលស្គាល់បរិក្ខារវិទ្យុទូរគមនាគមន៍**

**(Type Approval Per Model)** $

| | | |
|---|---|---|
| ទូរស័ព្ទចល័ត | ២,០០០ | (one time only) |
| ទូរសារ (Facsimile machine) | ១,៥០០ | (one time only) |
| បមាណី ( PABX ) | ១,៥០០ | (one time only) |
| ទូរស័ព្ទធម្មតា រី Wireless Phone | ១,៥០០ | (one time only) |
| ផេជិង (Pager) | ១,០០០ | (one time only) |
| បរិក្ខារវិទ្យុគមនាគមន៍ដទៃផ្សេងទៀត | ១,០០០ | (one time only) |
| ភ្នាក់ងារនាំចូលបរិក្ខារវិទ្យុទូរគមនាគមន៍ | ៨០០ | (one time only) |
| ការនាំចូលបរិក្ខារវិទ្យុទូរគមនាគមន៍សំរាប់ការងារផ្ទាល់ខ្លួន | ១០០ | (each time) |
| វិញ្ញាបនប័ត្រប្រចាំឆ្នាំ សំរាប់នាំចូល/លក់ បរិក្ខារវិទ្យុគមនាគមន៍ | ១០០ | |
| វិញ្ញាបនប័ត្រប្រចាំឆ្នាំ សំរាប់ជួសជុល/លក់បរិក្ខារវិទ្យុគមនាគមន៍ | ៥០ | |

ឧបសម្ព័ន្ធភ្ជាប់ប្រកាសលេខ : ៦៧៦ បទ.ប្រក ចុះថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០០៣

**ចាប់អនុវត្តន៍ពីថ្ងៃទី ១៥ ខែ សីហា ឆ្នាំ២០០៣**

**ឧបសម្ព័ន្ធទី៣**

**ការផាកពិន័យ**

សំគាល់ : ប្រាក់ពិន័យពុំមែនជាប្រាក់សំរាប់ទូទាត់តម្លៃអាជ្ញាប័ណ្ណទេ ។

១ ការប្រើប្រាស់បរិក្ខារវិទ្យុគមនាគមន៍មួយគ្រឿងទោះចល័តក្តី អចល័តក្តី ហើយគ្មានអាជ្ញាប័ណ្ណ ប្រាក់ពិន័យស្មើនឹង តំលៃអាជ្ញាប័ណ្ណប្រចាំឆ្នាំនៃបរិក្ខារនោះគុណនឹង ០.៥ ។

២ ការផ្លាស់ប្តូររលកអាកាសវិទ្យុ ដោយគ្មានការអនុញ្ញាតពីក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ ប្រាក់ពិន័យស្មើនឹង តំលៃអាជ្ញាប័ណ្ណប្រចាំឆ្នាំនៃបរិក្ខារនោះគុណនឹង ០.៤ ។

៣ ការផ្លាស់ប្តូរឋបនភ័ណ្ឌវិទ្យុគមនាគមន៍ ឬ ទីតាំងឋបនភ័ណ្ឌវិទ្យុគមនាគមន៍ដោយគ្មាន ការអនុញ្ញាតពីក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ ប្រាក់ពិន័យស្មើនឹង តំលៃអាជ្ញាប័ណ្ណប្រចាំឆ្នាំនៃបរិក្ខារនោះគុណនឹង ០.៣ ។

៤ ការប្រើប្រាស់អាជ្ញាប័ណ្ណហួសពេលកំណត់ ប្រាក់ពិន័យស្មើនឹង តំលៃអាជ្ញាប័ណ្ណប្រចាំឆ្នាំ នៃបរិក្ខារនោះគុណនឹង ០.២ ។

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

លេខ : ២៧៣ បទ-ប្រក

រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែ សីហា ឆ្នាំ 2003

# ប្រកាស

## ស្តីអំពីសេវាជួលខ្សែបរិវត្តទូរគមនាគមន៍អក្សរលេខ

## (Digital Leased Capacity)

### រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា.
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល.
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០-០៧-១៩៩៤ ដែលប្រកាសអោយប្រើប្រាស់ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី.
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ប្រកាសឱ្យប្រើដោយច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍.
- បានឃើញ អនុក្រឹត្យ ០៥អនក្រ ចុះថ្ងៃទី ០៥ ខែ មិនា ឆ្នាំ ១៩៨៧ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ស្តីពីប្រៃសណីយ៍ និងទូរគមនាគមន៍.
- បានឃើញ អនុក្រឹត្យលេខ ៦៦អនក្រ.បក ចុះថ្ងៃទី ២២-១០-១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍.
- បានឃើញ អនុក្រឹត្យលេខ ៨៦ អនក្រ/ប្រក ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០០២ ស្តីពីការកែសម្រួល និងបំពេញបន្ថែមនាយកដ្ឋានមួយចំនួននៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍.
- បានឃើញ អនុក្រឹត្យលេខ ០៥ អនក្រ/បក ចុះថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០០៣ ស្តីពីតម្លើងនាយកដ្ឋានរដ្ឋបាល និងបណ្តុះបណ្តាល ទៅជាអគ្គនាយកដ្ឋាន រដ្ឋបាល នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍.

- បានឃើញ សេចក្តីសំរេចលេខ ១៥៤សសរ ចុះថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ១៩៩១ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ស្តីពីឋានានុក្រមគ្រប់គ្រងតម្លៃ.
- យោងតាមស្មារតីនៃអង្គប្រជុំរបស់គណៈកម្មាធិការផែនការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០០២ និងអង្គប្រជុំ ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០០៣ ស្តីអំពីសេវាទូរគមនាគមន៍ សំរាប់ឆ្នាំ ២០០៣.

## សំ រេ ច :

**ប្រការ ១ :** កំណត់ថ្លៃសេវាជួលជាវបរិបថទូរគមនាគមន៍អក្ខរៈលេខក្នុងក្រុង រយៈផ្លូវឆ្ងាយក្នុងប្រទេស និងអន្តរជាតិ ដូចមានឧបសម្ព័ន្ធទី ១ ដល់ឧបសម្ព័ន្ធទី ៣ ភ្ជាប់ជាមួយនេះ ។

**ប្រការ ២ :** ប្រកាសទាំងឡាយណាដែលមានពីមុន ហើយមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៣ :** អគ្គនាយកដ្ឋានរដ្ឋបាល អគ្គនាយកដ្ឋានប្រៃសណីយ៍និងទូរគមនាគមន៍ ខុទ្ទកាល័យ អធិការដ្ឋាន គ្រប់នាយកដ្ឋានពាក់ព័ន្ធ និងគ្រប់មន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ខេត្ត-ក្រុងក្រោមឱវាទក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ត្រូវទទួលបន្ទុកអនុវត្តតាមតួនាទី ភារៈកិច្ចនូវប្រកាសនេះឱ្យមានប្រសិទ្ធិភាពខ្ពស់ ។

**ប្រការ ៤ :** ប្រកាសនេះចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**កន្លែងទទួល :**

- អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋាន រដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- រាជកិច្ច
- ក្រសួងផែនការ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាបជាព័ត៌មាន"
- ដូចប្រការ ៣
  "ដើម្បីអនុវត្តន៍"
- ឯកសារ-កាលប្បវត្តិ.

រដ្ឋមន្ត្រី

សូរ-ឃុន

**៣- ការប្រើប្រាស់បរិបថអន្តរជាតិបណ្តាញលើដី :**

សេវាបានត្រូវផ្តត់ផ្គង់សំរាប់ទិសដៅប្រទេសវៀតណាម និងប្រទេសថៃ ចំពោះក្រុមហ៊ុនការិបណ្តាញទូរគមនាគមន៍ដែលមានអាជ្ញាប័ណ្ណ និងអតិថិជនដែលមានការអនុញ្ញាតិប្រើប្រាស់ឯកជន ឬបំរើសាធារណៈ ។

៣.១- បានត្រូវអនុវត្តលក្ខណ្ឌត្រង់ចំណុច ២.១ និងថ្លៃបើកផ្លូវគ្រាដំបូង ត្រង់ចំណុច ២.២ ខាងលើ ។

៣.២- ថ្លៃជួលជាប្រចាំខែ តាមជំពោះល្បឿន និងចម្ងាយរយៈផ្លូវរវាងព្រំប្រទល់ប្រទេស បានត្រូវអនុវត្តតាមតារាង MATRIX ដូចឧបសម្ព័ន្ធ.២ និងចំណុច ២.៣ ខាងលើ ។

**៤- ការប្រើប្រាស់បរិបថអន្តរជាតិតាមប្រព័ន្ធស្ថានីយ៍ផ្កាយរណប :**

សេវាបានត្រូវផ្តត់ផ្គង់ចំពោះអតិថិជនដែលមានការអនុញ្ញាតិប្រើប្រាស់ឯកជន ឬបំរើសាធារណៈ ។ ថ្លៃប្រើប្រាស់ប្រចាំខែ និងថ្លៃស្ថាបនាគ្រាដំបូងរវាងមជ្ឈមណ្ឌលមាត់ច្រកអន្តរជាតិ គិតតាមចំណុះល្បឿន :

| | | | | | |
|---|---|---|---|---|---|
| ៤.១- | ចំណុះល្បឿន | 2.4Kbps = 1,400$/ខែ | ថ្លៃស្ថាបនា | = | 640$ |
| ៤.២- | ចំណុះល្បឿន | 4.8Kbps = 2,400$/ខែ | ថ្លៃស្ថាបនា | = | 800$ |
| ៤.៣- | ចំណុះល្បឿន | 9.6Kbps = 3,100$/ខែ | ថ្លៃស្ថាបនា | = | 1,040$ |
| ៤.៤- | ចំណុះល្បឿន | 19.2Kbps = 3,800$/ខែ | ថ្លៃស្ថាបនា | = | 1,280$ |
| ៤.៥- | ចំណុះល្បឿន | 48 ឬ 56 ឬ 64Kbps = 4,200$/ខែ | ថ្លៃស្ថាបនា | = | 1,600$ |
| ៤.៦- | ចំណុះល្បឿន | 128Kbps = 7,080$/ខែ | ថ្លៃស្ថាបនា | = | 1,920$ |
| ៤.៧- | ចំណុះល្បឿន | 192Kbps = 8,762$/ខែ | ថ្លៃស្ថាបនា | = | 2,240$ |
| ៤.៨- | ចំណុះល្បឿន | 256Kbps = 9,427$/ខែ | ថ្លៃស្ថាបនា | = | 2,400$ |
| ៤.៩- | ចំណុះល្បឿន | 384Kbps = 12,098$/ខែ | ថ្លៃស្ថាបនា | = | 3,500$ |
| ៤.១០- | ចំណុះល្បឿន | 512Kbps = 14,730$/ខែ | ថ្លៃស្ថាបនា | = | 3,500$ |
| ៤.១១- | ចំណុះល្បឿន | 768Kbps = 19,593$/ខែ | ថ្លៃស្ថាបនា | = | 3,500$ |
| ៤.១២- | ចំណុះល្បឿន | 1,024Kbps = 25,707$/ខែ | ថ្លៃស្ថាបនា | = | 3,500$ |
| ៤.១៣- | ចំណុះល្បឿន | 1,544Kbps = 31,737$/ខែ | ថ្លៃស្ថាបនា | = | 3,500$ |
| ៤.១៤- | ចំណុះល្បឿន | 2,048Kbps = 37,694$/ខែ | ថ្លៃស្ថាបនា | = | 3,500$ |

ប្រកាសលេខ ....៦៨៣........ បទ.ប្រក ចុះថ្ងៃទី .១៥.. ខែ សីហា ឆ្នាំ 2003



## ឧបសម្ព័ន្ធទី ២

## តារាង MATRIX

## ថ្លៃប្រចាំខែតាមរបៀបគម្រូគ្រង់ រវាងចំណុចចេញ និងចំណុចចូល

## ( Monthly Lease Between Origination Terminating Points)

ចាប់អនុវត្តពីថ្ងៃទី 15 ខែ សីហា ឆ្នាំ 2003

ចំណេះល្បឿន *1xE1* គិតជាប្រាក់ដុល្លា មួយខែ (USD)

| No | Orig\Term Point | Viet Nam | Thai land | Bavet | Svay Rieng | Neak Loueng | Phnom Penh | KG. Chhnang | Pur sat | Battam bang | Siso phon | Poipet | P.Net Preah | Kra lanh | Puok | Siem Reap |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| 01 | Vietnam | | 7,794 | 3,934 | 4,196 | 4,623 | 5,019 | 4,831 | 5,644 | 7,009 | 7,469 | 7,794 | 7,635 | 7,820 | 8,081 | 8,202 |
| 02 | Thailand | 7,794 | | 7,794 | 7,513 | 7,086 | 6,690 | 6,065 | 5,414 | 4,700 | 4,240 | 3,934 | 4,406 | 4,591 | 4,853 | 4,974 |
| 03 | Bavet | 3,934 | 7,794 | | 1,356 | 1,783 | 2,179 | 2,804 | 3,455 | 4,169 | 4,629 | 4,954 | 4,795 | 4,980 | 5,241 | 5,362 |
| 04 | Svayrieng | 4,196 | 7,513 | 1,356 | | 1,502 | 1,895 | 2,523 | 3,174 | 3,889 | 4,348 | 4,673 | 4,514 | 4,699 | 4,960 | 5,082 |
| 05 | Neakloeung | 4,623 | 7,086 | 1,783 | 1,502 | | 1,471 | 2,096 | 2,747 | 3,461 | 3,920 | 4,246 | 4,086 | 4,271 | 4,533 | 4,654 |
| 06 | PhnomPenh | 5,019 | 6,690 | 2,179 | 1,895 | 1,471 | | 1,700 | 2,351 | 3,066 | 3,525 | 3,850 | 3,690 | 3,876 | 4,137 | 4,259 |
| 07 | Kg.Chhnang | 4,831 | 6,065 | 2,804 | 2,523 | 2,096 | 1,700 | | 1,726 | 2,440 | 2,900 | 3,225 | 3.066 | 3,251 | 3,512 | 3,633 |
| 08 | Pursat | 5.644 | 5,414 | 3,455 | 3,174 | 2,747 | 2,351 | 1.726 | | 1,790 | 2,249 | 2,574 | 2,415 | 2,600 | 2,856 | 2,983 |
| 09 | Battambang | 7,009 | 4,700 | 4.169 | 3,889 | 3,461 | 3.066 | 2,440 | 1,790 | | 1,534 | 1.860 | 1,700 | 1.885 | 2,147 | 2.268 |
| 10 | Sisophon | 7.469 | 4,240 | 4.629 | 4,348 | 3,920 | 3,525 | 2,900 | 2,249 | 1,534 | | 1,400 | 1,241 | 1,426 | 1,687 | 1,809 |
| 11 | Poipet | 7,794 | 3,934 | 4,954 | 4,673 | 4,246 | 3,850 | 3,225 | 2,574 | 1,860 | 1,400 | | 1,566 | 1.751 | 2,013 | 2,134 |
| 12 | P.NetPreah | 7.635 | 4,406 | 4.795 | 4,514 | 4.086 | 3,690 | 3.066 | 2,415 | 1,700 | 1,241 | 1,566 | | 1,260 | 1,521 | 1,643 |
| 13 | Kralanh | 7,820 | 4,591 | 4.980 | 4,699 | 4,271 | 3,876 | 3,251 | 2,600 | 1,885 | 1,426 | 1,751 | 1,260 | | 1,337 | 1,458 |
| 14 | Puok | 8.081 | 4,853 | 5,241 | 4,960 | 4,533 | 4,137 | 3.512 | 2,856 | 2,147 | 1,687 | 2.013 | 1,521 | 1,337 | | 1,196 |
| 15 | Siemreap | 8.202 | 4,974 | 5.362 | 5,082 | 4.654 | 4,259 | 3,633 | 2,983 | 2,268 | 1,809 | 2,134 | 1,643 | 1.458 | 1,196 | |

**កំណត់សំគាល់** : ឥតបានគិតបញ្ចូលថ្លៃអាករ *VAT* ។

ប្រកាសលេខ ....២៧៣.... បទ.ប្រក ចុះថ្ងៃទី ១៥ ខែ សីហា ឆ្នាំ 2003 ទំព័រ : 5/5

## ឧបសម្ព័ន្ធទី ៣

## អត្ថន័យ និងលក្ខ័ណ្ឌសេវាជួលជាវបរិបថទូរគមនាគមន៍អក្ខរៈលេខ

## ( Terms and Conditions of Digital Leased Capacity )

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ បានបើកសេវាបំរើការជួលជាវបរិបថអក្ខរៈលេខតាមបណ្តាញកាប្លិ៍ *OPTIC* មានចំណុះល្បឿន និងប្រសិទ្ធិភាពខ្ពស់សំរាប់ភ្ជាប់គមនាគមន៍ពតិមានគ្រប់ប្រភេទក្នុងទីក្រុង-ទីរួមខេត្ត និងរយៈផ្លូវឆ្ងាយ *" ព្រំ ប្រទល់ប្រទេសថៃឡង់ត៍-ភ្នំពេញ-ព្រំប្រទល់ប្រទេសវៀតណាម "* និងរយៈផ្លូវសិរីសោភ័ណ - សៀមរាប-អង្គរ ។

សេវានឹងបានត្រូវផ្គត់ផ្គង់តាមរយៈនៃកិច្ចព្រមព្រៀងជូនបណ្តាក្រុមហ៊ុនការីបណ្តាញទូរគមនាគមន៍ ***(Network Operators)*** និងអតិថិជនដែលមានអាជ្ញាប័ណ្ណបំរើសាធារណៈ តាមអត្ថន័យ និង លក្ខ័ណ្ឌដូចខាងក្រោម :

១- **អត្ថន័យ** :

១.១- បណ្តាញកាប្លិ៍ *OPTIC* មានទម្រង់ជាបណ្តាញមួយ ឬច្រើនកំណាត់ ***( Segments )*** តាមការសន្មត់គិតពី " ចំណុចចុងទៅចំណុចចុង : *End to End* តាមបណ្តោយនៃរយៈផ្លូវបណ្តាញ ។

១.២- ការប្រើប្រាស់បណ្តាញកាប្លិ៍ *OPTIC* ឬការភ្ជាប់បន្តបណ្តាញ *(Interconnection)* គឺការតប្រគំបណ្តាញដទៃ ។ ***(Interface)*** ដោយភ្ជាប់ចូល ឬភ្ជាប់ចេញ នឹងបានត្រូវធានាអំពីអន្តរៈភាពប្រតិបត្តិការសេវា ***(Interoperability)*** ។

២- **ចំណុចភ្ជាប់បន្តបណ្តាញ** *(Interconnection Point )* :

២.១- ចំណុចភ្ជាប់បន្ត គឺ "ស្ថានីយ៍ក្បាលបណ្តាញ" ស្ថិតនៅមជ្ឈមណ្ឌលអង្គរ មហាវិថីសម្តេចព្រះសីហនុ ក្រុងភ្នំពេញ និង "ចំណុចបណ្តាញ" នៅតាមបណ្តាស្ថានីយ៍នៅ ប៉ោយប៉ែតទីរួមខេត្តបន្ទាយមានជ័យ សិរីសោភ័ណ បាត់ដំបង ពោធិសាត់ កំពង់ឆ្នាំង កំពង់ចម្លង អ្នកលឿងទីរួមខេត្តស្វាយរៀង និង ស្ថានីយ៍បាវិត ហើយនឹងមានបន្ថែមនៅឆ្នាំ 2003 ពីសិរីសោភ័ណទៅស្រុកព្រះនេត្រព្រះ ក្រឡាញ់ ពួក ដល់ទីរួមខេត្តសៀមរាប-អង្គរ ។ ចំណុចទាំងនោះអាចជាចំណុចបន្តចូល ***(Originating Point)*** ឬបន្តចេញ ***(Terminating Point)*** ។